ថ្នាក់មជ្ឈិមដ្ឋាន-ឧត្តមដ្ឋាន

# វេយ្យាករណ៍ខ្មែរ



សៀវភៅសម្រាប់សិស្ស

CA 23

បណ្ណាគារ គម-សេង

សៀវភៅ សម្រាប់សិស្ស

# វេយ្យាករណ៍ខ្មែរ

ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

GRAMMAIRE KHMERE COURS MOYEN ET SUPÉRIEUR

# វេយ្យាករណ៍ខ្មែរ

## ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

សៀវភៅសំរាប់សិស្ស

សាស្ត្រាចារ្យ ឡូវ-អ៊ុម

រៀបរៀង

---

ភ្នំពេញ

បណ្ណាគារ គិម-សេង លេខ ១២២ វិថីអារម៉ង់ដ័រូស្សូ

ព.ស. ២៤៩៨ គ.ស. ១៩៥៥

---

រក្សាសិទ្ធិ

# សេចក្ដីផ្ដើម និង ការយល់ព្រម

ការកើតឡើងជាវិធីអក្ខរៈនេះ ដោយសារខ្ញុំយកចិត្តទុកដាក់ជាតិកំណើតរបស់ខ្ញុំជាទីស្រឡាញ់ ព្រោះការធ្វើនេះ គឺធ្វើដោយចិត្តឯង ពុំបានគិតកម្លាំងនឿយលំបាកឡើយ ។

វិធីអក្ខរៈនេះ រៀបតែនឹងបោះបង់ចោលអសារឥតការទៅហើយ ស្រាប់តែលោក អ៊ុម - ឈាងស៊ុន ទីប្រឹក្សាព្រះរាជ. អាណាចក្រ កាលលោកនៅជាចាងហ្វាងក្រសួងសិក្សាធិការក្រុងភ្នំពេញ លោកមានចិន្តារៀបចំវិជ្ជាខេមរភាសាឲ្យបានរៀបរយ ទើបលោកឲ្យខ្ញុំយកការដ៏តិចតួចនេះជូនទៅលោក ។

ក្បួននេះមានកំណើតជាដំបូងបំផុត របៀបវេយ្យាករណ៍ពុំបានជាប្រសើរណាស់ណាឡើយ តែខ្ញុំសូមដឹងគុណលោក អ៊ុម - ឈាងស៊ុន ជាទីបំផុតដោយសេចក្ដីដែលលោកកប់អានការតិចតួចរបស់ខ្ញុំមិនឲ្យសោះសូន្យ ។ លោកក៏បានចាត់ចែងឲ្យក្រុមវិទ្យាសាស្ត្រ ក្រសួងសិក្សាធិការ ពិនិត្យបោះពុម្ពផ្សាយតាមរយៈរាជការ ពីឆ្នាំរកាស័ក ព.ស. ២៤៨៨ ម្ដងរួចហើយ ។

ដល់មកថ្ងៃទី ១ ខែសីហា គ.ស. ១៩៥០ នេះ រោងពុម្ពខេមរវត្ត ក្រុងភ្នំពេញ បានទៅសុំសៀវភៅនេះអំពីខ្ញុំជាអ្នករៀបរៀង ដើម្បីនឹងយកទៅចាត់ចែងបោះពុម្ពទុកបម្រើដល់សិក្ខាកាម-កុលបុត្រ ដែលស្រេកក្នុងការសិក្សាអក្សរសាស្ត្រខ្មែរ ជាវយកទៅសិក្សារៀនសូត្រឲ្យបានសម្រេចតាមបំណង ។

ខ្ញុំក៏បានយល់ព្រម អនុញ្ញាតឲ្យរោងពុម្ពខេមរវត្តបោះពុម្ពសៀវភៅនេះ តាមសេចក្ដីត្រូវការ ដោយសេចក្ដីសង្ឃឹមថា អក្សរសាស្ត្រខ្មែរ នឹងបានឡើងកាន់វឌ្ឍនធម៌លូតលាស់ដុះដាលស្មើៗនឹងគេទៅអនាគត ។

ព. ស. ២៤៩៣ គ. ស. ១៩៥០

ញូវ · អ៊ុម




១ – វេយ្យាករណ៍ខ្មែរជាក្បួនបង្រៀនវិធីអក្ខរៈ ដើម្បីនិយាយត្រឹមត្រូវ សរសេរត្រឹមត្រូវក្នុងភាសាខ្មែរ ។ ក្បួនវេយ្យាករណ៍ច្រើនតែរៀបរៀងតាំងពីព្យញ្ជនៈ ។

អក្ខរៈ ឬអក្សរ ឬវណ្ណៈ មានពីរយ៉ាងគឺ៖ ស្រៈ ឬសរៈ និងព្យញ្ជនៈ ។ ស្រៈមានពីរពួក ស្រៈពេញតួ និងស្រៈនិស្ស័យ ។

ស្រៈពេញតួមាន ១៤ គឺ៖ អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

ស្រៈនិស្ស័យមាន ២០ តួគឺ ា ិ ី ឹ ឺ
ើ ឿ ៀ េ ែ ៃ ោ ៅ ុ ូ ុំ ំ ាំ ះ ់ ៉ ៊ ។

ព្យញ្ជនៈមាន ៣៣ តួគឺ៖ ក ខ គ ឃ ង ច ឆ ជ ឈ ញ ដ ឋ ឌ ឍ ណ ត ថ ទ ធ ន ប ផ ព ភ ម យ រ ល វ ស ហ ឡ អ ។

## ៣ — ថ្នាក់ មធ្យមដ្ឋាន នឹង ឧត្តមដ្ឋាន

ដែលហៅថាស្រៈពេញតួនោះ គឺស្រៈប្រើជាតួអក្ខរៈដូចតួព្យញ្ជនៈដែរ ដូចពាក្យថា: អរគុណ អាប ឥឡូវ កៅអី ឧត្តម ឧស្សាហ៍ ឪឡឹក ឪឡោក ឫក្ស ឫស្សី ឫទ្ធិ ឭក្ខេ? ឯក ឯនោះ ឭដំ ឭព ឲ្យ ឱដ្ឋ ឱស្ឋ អក អក់ អាចម៍ ក្រឪ អាវ ឥត ។

ដែលហៅថាស្រៈនិស្ស័យនោះព្រោះអាស្រ័យនឹងតួព្យញ្ជនៈ



ទើបប្រើបាន ដូចពាក្យថា: តាម ដឹង ចុង កុដិ សូម លេង កាំបិត ប្រែង កន្ទើយ ព្រាដើយ សម្បើម ទង់ទាញ ។

## ២ — ព្យញ្ជនៈ

ព្យញ្ជនៈទាំង ៣៣ ចែកជា ៥ វគ្គបូក នឹងសេសវគ្គ ១ ។ វគ្គនិមួយៗ មានអក្សរ ៥ តួ, ឯសេសវគ្គមានអក្សរ ៨ តួ ។ វគ្គទី ១ គឺ: ក ខ គ ឃ ង ។ វគ្គទី ២ គឺ: ច ឆ ជ ឈ ញ ។ វគ្គទី ៣ គឺ: ដ ឋ ឌ ឍ ណ ។ វគ្គទី ៤ គឺ: ត ថ ទ ធ ន ។ វគ្គទី ៥ គឺ: ប ផ ព ភ ម ។

សេសវគ្គគឺៈ យ រ ល វ ស ហ ឡ អំ ។

ព្យញ្ជនៈទាំងឡាយមានស័ព្ទសំឡេងជាពីរពួក ពួកសំឡេងតូចហៅថាអឃោសៈ ពួកសំឡេងធំហៅថាឃោសៈ ។

## អក្សរអឃោសៈ

ក ខ - ច ឆ - ដ ឋ - ត ថ - ប ផ - ស ហ - ឡ អ ។

## អក្សរឃោសៈ

គ ឃ ង - ជ ឈ ញ - ឌ ឍ ណ - ទ ធ ន - ព ភ ម - យ រ ល វ ។

អក្សរនៅចុងវគ្គទាំង៥ និងនៅចុងសេសវគ្គឈ្មោះនិគ្គហិតគឺ ង ញ ណ ន ម អំ ។ តួព្យញ្ជនៈទាំងឡាយមានសំឡេងប្លែកពីគ្នាៈ តួខ្លះមានសំឡេងតែមួយ តួខ្លះមានសំឡេងផ្សំ ។ តួដែលមានសំឡេងព្ទតែមួយហៅថាសិថិល, តួដែលមានសំឡេងផ្សំហៅថាធនិត ។

## អក្សរសិថិល

ក គ - ច ជ - ដ ឌ - ត ទ - ប ព - យ រ ល វ ស ហ

និងនិគ្គហិតង ញ ណ ន ម អំ ។

## អក្សរធនិត

ខ ឃ - ឆ ឈ - ឋ ឍ - ថ ធ - ផ ភ ។

---

## ៣ — គូអក្សរ

ក្នុងវគ្គនិមួយ ៗ មានអក្សរជាគូគ្នាពីរគូនោះគឺ:

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វគ្គទី | ១ | អក្សរ | ក | ជាគូនឹងអក្សរ | ខ | ។ | គ | ជាគូនឹង | ឃ |
| ,, | ២ | ,, | ច | ,, | ឆ | ។ | ជ | ,, | ឈ |
| ,, | ៣ | ,, | ដ | ,, | ឋ | ។ | ឌ | ,, | ឍ |
| ,, | ៤ | ,, | ត | ,, | ថ | ។ | ទ | ,, | ធ |
| ,, | ៥ | ,, | ប | ,, | ផ | ។ | ព | ,, | ភ |

ឯអក្សរនៅសេសវគ្គជាគូសិថិលទាំងអស់ ឥតមានគូឡើយ នឹងអក្សរនៅខាងចុងវគ្គទាំង៥ ក៏ជាសិថិលឥតមានគូដូចគ្នាដែរ ។ អក្សរឥតគូ ឬអក្សរពោលទាំងនោះគឺ ង ញ ណ ន ម យ រ ល វ ស ហ ឡ អំ ។

## ៤ – ព្យញ្ជនៈបន្ថែម

ដើម្បីនឹងប្រើការឲ្យគ្រប់គ្រាន់ក្នុងភាសា បុរាណាចារ្យលោកបន្ថែមព្យញ្ជនៈដោយថែមវណ្ណយុត្តិមូសិកទន្ត ទឹងត្រីសព្ទលើព្យញ្ជនៈ ១៖ ព្យញ្ជនៈទាំងនោះគឺ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ ប៊ ស៊ ហ៊ អ៊ ។ ព្យញ្ជនៈទាំងនេះបើកាលណាមានស្រៈនិស្ស័យ ិ ី ឹ ឺ ើ ភ្ជាប់លើក្ដី គេផ្លាស់វណ្ណយុត្តិ ៉ ៊ ជា ុ ដូចពាក្យៈ ប៉ិន ម៉ីន រ៉ឹ ប៊ឺ ស៊ី ហ៊ឹង អ៊ី ។

---

## ៥ – វណ្ណយុត្តិ

សញ្ញាដែលបន្ថែមលើអក្ខរៈ ដើម្បីនឹងសំអៀងស័ព្ទវែងជាស័ព្ទខ្លី ឬសំអៀងស័ព្ទឲ្យប្លែកពីស័ព្ទដើម ឬកាត់ពាក្យក្នុងប្រយោគជាសង្កាត់ដើម្បីឲ្យលះសេចក្ដីហៅថាវណ្ណយុត្តិ ។ វណ្ណយុត្តិទាំងឡាយគឺ បន្តក់ (់) មូសិកទន្ត (៉) ត្រីស័ព្ទ (៊) សំយោគសញ្ញា (័) របាទ (៌) អស្ដា (៏) ទណ្ឌឃាត (៍) វិសជ្ជនីយ (ះ) កុក្កុដនេត្រ (៦) កាកបាទ (+) វង់ក្រចក (()) អត្តន្តរ· ("..") លះ (ฯលฯ)

## ៥–បុ៉ាក់ មជ្ឈិមដ្ឋាន នឹង ឧត្តមដ្ឋាន

(មកពីពាក្យបេយ្យាលៈ គេយកតែអក្សរ ល ខាងចុង) គោមូត្រ ឬបរិយោសាន (៚—) ខណ្ឌ (ៗ)

---

## ៦–វិធីប្រើវណ្ណយុត្តិ

បន្តក់–សញ្ញានេះ សំរាប់ដាក់ថែមលើតួប្រកប ដែលព្យាង្គពាក្យកើតឡើងពីស្រៈ អ នឹងស្រៈអា ហើយកាត់ស័ព្ទវែងជាស័ព្ទខ្លី ដូចពាក្យៈ បង ស័ព្ទវែង, បង់ ស័ព្ទខ្លី; ចាក ស័ព្ទវែង, ចាក់ ស័ព្ទខ្លី, ឃាត ស័ព្ទវែង, ឃាត់ ស័ព្ទខ្លី ... ឯអក្សរជាតួប្រកបរបស់ព្យាង្គពាក្យ ហើយទទួលសញ្ញាបន្តក់ (់) បានមានតែអក្សរទាំងនេះ ក ង ច ញ ត ន ប ល ស ។ អក្សរក្រៅពីនោះទៅ ទោះកាត់ស័ព្ទវែងជាខ្លីក៏ដោយ មិនដែលទទួលវណ្ណយុត្តិបន្តក់ (់) ឡើយ ដូចពាក្យៈ បទ បថ សព្វ គត ... ប៉ុន្តែបើពាក្យណាដែលចេញមកពីបាលីឬសំស្រ្កឹត នោះអក្សរដែលត្រូវទទួលបន្តក់ (់) បាន ក៏ពុំត្រូវដាក់បន្តក់ (់) ឡើយ ដូចពាក្យៈ កុសល ផល លាមក ធនធាន ជន សត្វ ខត្ត ក្សត្រ ។





មូសិកទន្ត– សញ្ញានេះ សំរាប់ថែមលើអក្សរនៅដើម
ព្យាង្គពាក្យ កាលណាពាក្យនោះគ្មានព្យាង្គឯទៀតបន្ថែមមក ឬ
ព្យាង្គនោះទោលគឺជាប់តែឯង ដូចពាក្យ ប៉ុន្តែ ប៉ុណ្យស៊ាន ម៉ក់
ញ៉ាំ ញ៉ី បើកាលណាមានស័ព្ទព្យាង្គដើម ឬតួអក្សរដើមបន្ថែមមក
មិនត្រូវដាក់មូសិកទន្ត (") ឡើយ ដូចពាក្យៈ ប្រមោយ ស្រវឹង
បម្បា បម្រុក ប្រមាទ សង្កាត ក្នុង ខ្ទឹម ច្នា ត្នាត.... ។

ត្រីស័ព្ទ – វិធីប្រើវណ្ណយុត្តិត្រីស័ព្ទ មានលំនាំដូចគ្នានឹង
មូសិកទន្តដែរ ដូចពាក្យៈ ទ្រហឹង គ្រហា វិហារ ពាហាន ។
ស៊ី ហ៊ឹងត្រចៀក អ៊ុត ហ៊ាន ស៊ុន ស៊ើបការ ... ។

# ៨–ថ្នាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

សំយោគសញ្ញា – វណ្ណយុត្តិនេះ សំរៀនស័ព្ទបាលី ឬសំស្ក្រឹតមកជាស័ព្ទខ្មែរ ។ ឧបមាដូចពាក្យៈ (ភយ) ភ័យ; (ជយ) ជ័យ; (ខយំ, ក្សយ) ខ័យ, ក្ស័យ; (ពន្ធ) ព័ន្ធ; (ពទ្ធ) ព័ទ្ធ; (យន្ត, យន្ត្រ) យ័ន្ត, យ័ន្ត្រ; យន្ត (យន់), (សម្បទ) សម្ប័ទ, សម្បត្តិ; (បច្ចយ); បច្ច័យ (អាលយ) អាល័យ; (សមយ) សម័យ; (សំសយ) សង្ស័យ; (ហទយ, ហឫទយ) ហ័ទយ, ហ្ឫទ័យ ។

សញ្ញានេះប្រើនូវពាក្យខ្មែរខ្លះដែរ កាលណាពាក្យនោះមិនពេញលេញ ជាពាក្យកើតមកពីស្រៈ អ ឬ អា ហើយអក្សរជាគូប្រកប ដូចពាក្យថាៈ ជ័រ ញ័រ ទំព័រ ទទឹទទ័រ ព្រឺព្រ័រ សាសន៍ព័រ ញញាក់ញញ័រ ... ។

វិរាម – សញ្ញានេះជំនួស រ កាលណា រ ជាជំនួសគូអក្សរតម្រួត ។ របាទ (៌) ជាវណ្ណយុត្តិសំរាប់ដាក់ នូវពាក្យសំស្ក្រឹតក្លាយមកពីបាលី ។ ជាធម្មតា គូអក្សរណាដែលពុំសូវប្រើជាជើង ដើរជាគ្រាប់ គូតម្រួតអក្សរនោះផ្លាស់ជារបាទ ។ បើគូអក្សរណា



ធ្លាប់ប្រើ ត្រពត់ក្នុងផ្ទើដើង តួតម្រួតអក្សរនោះផ្លាស់ជាត្រពត់ ។
តួតម្រួតផ្លាស់ជា រ ក៏បាន ដូចមានពាក្យទាំងនេះជាបែបយ៉ាង ៖
ណ្ណ = ណ៌, ម្ម = ម៌, ត្ត = ត៌, ត្ថ = ត៌, ពណ្ណ = ពណ៌, ធម្ម = ធម៌,
តក្ក = តក៌, បុញ្ញ = បូញ៌, បរិបុណ្ណ = បរិបូណ៌ = បរិបូរណ៌ ។
មានអក្សរខ្លះដែលធ្លាប់មានផ្ទើដើងត្រពត់ ជាប់ដោយសញ្ញារបាទខ្លះ
ក៏មានដែរ ដូចពាក្យៈ កក្កដ ជា កក៌ដ; វិសជ្ជនីយ ជា វិសជ៌នីយ,
មគ្គុទ្ទេស ជា មគ៌ុទេស, មគ្គ ជា មាគ៌, មារយាទ ជា មាយ៌ាទ ។

កំណត់កត់សំគាល់ – ក្ក = ក្រ, គ្គ = គ្រ, ទ្ទ = ទ្រ,
ស្ស = ស្រ ដូចពាក្យៈ បក្ក = បក្រ, ខត្ត = ក្សត្រ, បុត្ត = បុត្រ,
សមុទ្ទ = សមុទ្រ... ប៉ុន្តែតួអក្សរដទៃពីរតួ ដូចពោលខាងលើ
នេះមិនផ្លាស់តួតម្រួតជា "រ" ទៀយ ។

## ១០ — ប្នាក់ មជ្ឈិមង្គន និង ឧត្តមង្គន

អស្តា — សញ្ញាអស្តា ប្រើដាក់តែលើអក្សរ ក និង

ហើយ ក និង ដ នោះជាពាក្យនិបាត គឺពាក្យនោះមិនមែនជា

នាម ជាគុណនាមឬជាកិរិយាស័ព្ទ ដូចពាក្យថា: ទោះហាមដូ

ម្តេច ក៏មិនស្តាប់ ។ អ្នកនេះធម៌ដ៏ប្រសើរ រមែងរួចពាក

អបាយភូមិ ។ ប្រសើរដ៏ឧត្តម ។

ក្នុងពាក្យឧទានស័ព្ទ គឺពាក្យថាដោយភ្ញាក់ផ្អើល សញ

នេះ មានប្រើខ្លះដែរ ដូចពាក្យ: ឧហ៏ ! ឧនឹ ! នុះហ៏ ប្អូនឹ ! ។

ទណ្ឌឃាត — ទីដបដិសេធតួអក្សរលើសពីការ គេដាក

ទណ្ឌឃាត: រតន៍, ទោទក៍, ពេទ៍, ប្រយោជន៍ ... ។

វិសជ្ជនីយ — សញ្ញានេះប្រើជំនួសខ្យល់ “ស” ស័ព្ទ

នេះ, ព្រោះ, ដះ.... ។

កុកដិនេត្រ — សញ្ញានេះ សម្រាប់ប្រើផ្តើមសេចក្តី ។

កាកបាទ — សម្រាប់ប្រើពាក្យឧទានសព្ទ និងពាក្យ

វិសេសនសព្ទនាមខ្លះ ដូចពាក្យថា: ចា៎ះ ! ហា៎ ! នុ៎ះ ។

វង់ក្រចក — សញ្ញាវង់ក្រចកសំរាប់ដាក់គៀបពាក្យណា ឬឃ្លាណាមួយ ដែលមិនមានទាក់ទងចូលក្នុងអត្ថបទនោះទេ គ្រាន់តែជាស័ព្ទពន្យល់ពាក្យណាមួយ ដែលមានក្នុងអត្ថបទនោះៗ ដូចពាក្យថា: បិតាខ្ញុំអញ្ជើញទៅប្រទេសថៃឡង់ដ៍ (ប្រទេសសៀម) តាំងពីខែមេសាម្ល៉េះ ។

អព្ភន្តរៈ — សញ្ញាអព្ភន្តរៈ សំរាប់ដាក់គៀបឃ្លាណាដែលមានសារប្រយោជន៍ច្រើន ឬឃ្លាណាដែលអ្នកនិពន្ធចង់ឲ្យអ្នកអានយកចិត្តទុកដាក់ប្រុងការឃ្លានោះជាង ដូចពាក្យថា: ខេមរជនយើងដឹងគ្រប់គ្នាថា “ចេះពីរៀន មានពីរក” ប៉ុន្តែមិនមានជនណាមួយ ខំអនុវត្តតាមពាក្យទំនៀមនោះសោះ ។

លៈ ។ ល ។ — សញ្ញាលៈ (។ ល ។) នេះ សំរាប់ប្រាប់ថាពាក្យដែលគេរាប់រៀបនោះ មិនទាន់អស់ទេនៅមានតទៅទៀត ។

គោមូត្រ ឬ បរិយោសាន — សញ្ញានេះ សំរាប់បញ្ចប់សេចក្ដីជាស្រេចឥតមានតទៅទៀត ។

ខណ្ឌ – សញ្ញាខណ្ឌនេះ សំរាប់ដាក់សេចក្ដីសង្កត់ៗ ដើម្បីធ្វើសេចក្ដីនោះឲ្យល្អស្ដាប់ ។

---

## ៧ – អក្សរព្យញ្ជនៈផ្លាស់ប្ដូររូប

តួអក្សរផ្លាស់ប្ដូររូប កើតឡើងអំពីពាក្យបាលី ដែលក្លាយទៅជាពាក្យសំស្ក្រឹត ពាក្យទាំងនោះខ្មែរប្រើទាំងបាលីទាំងសំស្ក្រឹត ៗ ន័យរបស់ពាក្យដូចគ្នា ៗ ស័ព្ទនឹងរូបអក្សរដូចគ្នា ៗ តួផ្លាស់ប្ដូររូបទាំងឡាយនោះ ទឹងសំរេចជាក្បួនដាច់ស្រេចពុំបាន មានតួខ្លះផ្លាស់ខុសរបៀបក៏មាន ប៉ុន្តែការផ្លាស់តួជាញឹកញយនោះ ដូចមានពាក្យឧបមាទាំងនេះ អក្ខរៈផ្លាស់ជាអក្សរ, យក្ខៈ ជាយក្ស, រុក្ខៈ ជាព្រឹក្ស, សិក្ខា ជាសិក្សា, ខត្តៈ ជាក្សត្រ, ខេត្តៈ ជាក្សេត្រ, ខេមៈ ជាក្សេម, ខណៈ ជាក្សណៈ, ខីរៈ ជាក្សីរ, និច្ចៈ ជានិត្យ, កិច្ចៈ ជាក្រឹត្យ, អាទិច្ចៈ ជាអាទិត្យ, វិនិច្ឆ័យ ជាពិនិស្ច័យ, អច្ឆរិយៈ ជាអស្ចារ្យ, បច្ឆិមៈ ជាបស្ចិម, វិជ្ជា ជាវិទ្យា, វេជ្ជៈ ជាវេទ្យ, សម្មោជ្ជៈ ជាសម្មោទ្យ-សាមោទ្យ, មជ្ឈិមៈ ជាមធ្យម, ឈានៈ ជាធ្យាន, ជេដ្ឋៈ

ជាជេស្ឋ, អធិដ្ឋានៈ ជាអធិស្ឋាន, ព្រះឱដ្ឋៈ ជាព្រះឱស្ឋ បិតៈ ជា ស្ថិត, ឋានៈ ជា ស្ថាន, ថនៈ ជា ស្តន, ព្រះហត្ថៈ ជា ព្រះហស្ត, រដ្ឋៈ ជារាស្ត្រ ។ អត្ថៈ ជាអាថ៌ . . . បក្កៈ ជា បក្រ, បុត្តៈ ជាបុត្រ, រត្តិ ជារាត្រី, មេត្តា ជា មេត្រី ។ សមុទ្ទៈ ជា សមុទ្រ, ភទ្ទបទៈ ជា ភទ្របទ, វេស្សវណ្ណៈ ជា វៃស្រវណ, ធម្មៈ ជា ធម៌, មគ្គៈ ជា មាគ៌, បុព្វៈ ជា បូព៌, បរិបុណ្ណៈ ជា បរិបូណ៌ ឬ បរិបូរណ៍, បុណ្ណមី ជា បូណ៌មី, គព្ភៈ ជា គភ៌, ទុគ្គតៈ ជា ទុគ៌ត ឬ ទុរគត, ។

## ៨– វិធីស្វាធ្យាយ៍តបំមាត់

ក្ខ ផ្លាស់ជា ក្ស, ច្ឆ ផ្លាស់ជា ត្ស, ច្ឆ ផ្លាស់ជា ស្ច, ជ្ឈ ផ្លាស់ជា ទ្យ, ជ្ឈ ផ្លាស់ជា ធ្យ, ដ្ឋ ផ្លាស់ជា ស្ឋ; ឋ ផ្លាស់ជា ស្ថ ។ ក្ក តម្រូតជា ក្រ, ត្ត តម្រូតជា ត្រ, ទ្ទ តម្រូតជា ទ្រ ។ ម្ម តម្រូវជា ម៌, ណ្ណ តម្រូតជា ណ៌, ព្វ តម្រូតជា ព៌, គ្គ តម្រូតជា គ៌, ទ្ទ តម្រូតជា ទ៌, ព្ភ តម្រូតជា ភ៌ ។

មានពាក្យខ្លះកើតពីអក្សរ វ ទីង ព ផ្លាស់ប្តូរគ្នា ដូចពាក្យ ...ាៈ វាទ វាចា ជា វាក្យ ឬ ពាក្យ, វេលា វិលា ជាពេល,

វនៈ ជាពន (ព្រៃ), វរៈ ជា ព្រះ, វ្ឫក្សៈ ជាព្រឹក្ស, វិសៈ ជា វិស្ស ឬ ពិស្ស, វិសាខៈ ជា ពិសាខ, វ្ឫហស្បតិ ជា ព្រហស្បតិ, ទក្ខិណៈ ជា ទក្សិន, ហេមវន្តៈ ជាហេមពន្ត... ។

ពាក្យខ្លះទៀតដូច: សត្តៈ ជាសត្វ, សតវស្ស ជា សតវត្ស ឬ វត្សរ៍, បៀវស្សៈ ជា បៀវត្ស... ។

---

## ៩ – វណ្ណយុត្តិ – មេសូត្រ (ព្រហ្មគីត)

អ្នកអើយសិស្សា ត្រូវសិក្សាបេះឲ្យមុត
ឲ្យស្គាល់គ្រឿងវណ្ណយុត្តិ ប្តូរខុសព្យាក់គិតរំពឹង ។

( ' បន្តក់ )

សញ្ញាមួយនោះណា រាងរូបាទ្រង់ដូចស្នឹង
បន្តក់វណ្ណយុត្តិហ្នឹង កាត់ស័ព្ទវែងជាស័ព្ទខ្លី ។

( '' មូសិកាទន្ត )

ស្នឹងពីរដាក់ទឹមគ្នា លើអក្ខរាប្រែសំដី
ឈ្មោះមូសិកទន្តី ធ្មេញកណ្ដុរចូរចាំទុក ។

( ័ សំយោគសញ្ញា )

វណ្ណយុត្តិមួយនោះនៃ    កាន់ឧបមេយ្យដូចជាក្អុក
គងសារ “ង” ទៅមុខ    ហៅថាសំយោគសញ្ញា ។

( ៌ របាទ )

របាទជាវណ្ណយុត្តិ
ត្រូវសន្មតជំនួស “រ”
ទ្រង់ទ្រាយក្រងក់ “ង”
ដូចលំនាំកក្រសារ ។



( ៏ អស្ដា )

សញ្ញាមួយវិញនោះ    អស្ដាស្មោះកង់គាយា
អ្នកប្រាជ្ញបញ្ញត្តថា    ឲ្យប្រើលើ “ដ” និង “ក” ។

( ៍ ទណ្ឌឃាត )

ទណ្ឌឃាតសម្លាប់ចង់    តួមួយអង្គនៃអក្ខរា
ដែលលើសពីស័ព្ទថា    តាមតម្រាគេឥតពោល ។

# ១៦ – ឃ្នាក់ មជ្ឈិមឃ្នាន និង ឧត្តមឃ្នាន

( ះ វិសជ្ជនីយ )

វិសជ្ជនីយស-ញ្ញានោះព្រួសព្ទជាអះ ដូចប្រើពាក្យ "ទោះ"
"ខ្វះ" "មោះ" "សោះ" "បោះ" សឹងក្បៀលពីរ ។

( ៙ កុក្កុដនេត្រ )

សញ្ញាវង់ភ្នែកមាន់ ចូរកុំកាន់ក្នុងដួងថៃ
អ្នកប្រាជ្ញលោកតែង ទុកជាដើមផ្ដើមសេចក្ដី ។

( + កាកបាទ )

កាកបាទខ្វៀងដើមភ្នែក ជាចំណែកសញ្ញាទោល
ឋិតលើពាក្យពាំនោល ដូចជា ប៉ា៎ះ នុ៎ះ ណា៎នៃ ។

( ( ) វង់ក្រចក )

ពាក្យខ្វះគួរបដិសេធ តែដោយហេតុលុបមិនបាន
ហ្នោះហើយទុកឲ្យមាន ដាក់នៅក្នុងវង់ក្រចក ។

( "..." អព្ភន្តរៈ )

សញ្ញាជាក្រោយនេះ នាមជាអព្ភន្តរី
ប្រក្បៀកពាក្យក្នុងទី ដែលត្រូវឃើញយល់ជាក់ស្ដែង ។

(។ល។ លៈ)

មាតិកាសំដែងវែង　　គេបាំងទុកលៃលក
ដាក់ប្រួមពាក្យនោះមក　　គំណាន់ជាសញ្ញាលៈ ។

(៙— បរិយោសាន)

បរិយោសានសោត　　ម្តងគោមូត្រចប់សំដី
សំដែងរឿងអ្វីៗ　　ចូរយើងដឹងដោយដំណើរ ។

(។ ខណ្ឌ)

ខណ្ឌសញ្ញាគាត់　　ជាសង្កាត់បាកស្នាក់ស្ទើរ
ឲ្យសេចក្តីប្រសើរ　　ឯរូបភាពដូចឈើច្រាន ។

(- យតិភង្គ)

សញ្ញាជាបណ្តាច់　　ក្រោយសំរេចមួយនេះឯង
ភ្ជាប់បាទកាព្យតាមបែង　　ដែលព្យាង្គបែកចេញពីគ្នា ។
រីឈ្មោះសញ្ញានោះ　　ចូរចាំចុះកុំគន្សា
យតិភង្គនាមា　　ដកបទៅកុំបីផ្លាយ ។

## ១០ — មុខងារនៃអក្សរ

ពាក្យដែលយើងនិយាយមួយម៉ាត់ៗ ពោះពាក្យមានតួអក្សរប្រកបក្តីពាក្យគ្មានតួអក្សរប្រកបក្តីហៅថាព្យាង្គ ព្យាង្គដែលមានអក្សរជាតួប្រកបសម្រាប់ព្យាង្គនោះ គឺជានឹងផ្លាស់ប្តូរតួប្រកបពុំបានឡើយ ៗ ឧបមាដូចពាក្យ: មុខ-មគ្គ-សព្វ-សុខ-ជ្រាប-ទើប ...: នឹងសរសេរ: មុក-មាក់-សប់-សុក-ជ្រាព-ទើព ... ដូច្នេះវិញពុំបានឡើយ ៗ ភាសាខ្មែរប្រជុំនៃភាសា ៣ គឺ: ភាសាអ្នកស្រុក, ភាសាបាលី នឹងភាសាសំស្ក្រឹត ៗ វេយ្យាករណ៍បែកមុខងារអក្សរព្យញ្ជនៈដាច់ស្រឡះ នោះអក្សរជាតួប្រកបនូវពាក្យខ្មែរ សឹងជាអក្សរនៅដើមវគ្គគឺ: ក ច ដ ត ប ៗ អក្សរប្រកបនូវពាក្យបាលីដែលប្រើក្នុងភាសាខ្មែរ ឬពាក្យសំស្ក្រឹតក្តី សឹងជាអក្សរទី ២ ទី ៣ ទី ៤ ក្នុងវគ្គគឺ: ខគឃ ឆជឈ ឋឌឍ ថទធ ផពភ ៗ ឯអក្សរនៅចុងវគ្គ នឹងអក្សរនៅសេសវគ្គគឺ: ងញណនម យរលវ សហឡ ប្រើបានជាតួប្រកបនូវពាក្យខ្មែរ

ពាក្យបាលីនិងពាក្យសំស្រ្កតជាមួយគ្នា ។ ន័យមួយវិញទៀត អក្សរទាំងឡាយដែលចាត់ជាតួប្រកបនូវពាក្យមកពីបាលីឬសំស្រ្កត អក្សរទាំងនោះមិនត្រូវមានសញ្ញាបន្តក់ថែមពីលើឡើយ ។ ទោះពាក្យនោះមានសព្ទទូកក៏ដោយ ដូចពាក្យ : សព សព្វ ផល កុសល ជន ធនធាន ពុល ប្រាកដ សន្ទូត លាមក ជាដើម ។

## ១១ — ព្យាង្គរបស់ពាក្យ

តួអក្សរផ្សំគ្នា ឬតួនិងស្រៈផ្សំគ្នា កើតឡើងជាពាក្យ ពាក្យទាំងនោះ ពាក្យខ្លះមានព្យាង្គតែមួយ ពាក្យខ្លះមានព្យាង្គ ២ ឬហៅពាក្យពីរព្យាង្គ ពាក្យខ្លះបីព្យាង្គ ពាក្យខ្លះមានព្យាង្គច្រើនទៀត ។ ព្យាង្គគេហៅឬពាក្យព្យាង្គតែមួយ: ចាស់ - នៅ - ទឹក - ផ្ទៃ - លេង ។ ពាក្យពីរព្យាង្គ : លំនៅ - បំណោទ - បន្ទា - សណ្តែក ... ។ ពាក្យបីព្យាង្គ: បម្រាជាក់ - បន្ទាទូក - គន្ទេះឡង់ ... ។ ពាក្យច្រើនព្យាង្គ : អម្ពិលអំពែក - ទោសានុទោស - ថេរានុត្ថេរ: - រាជកិច្ចានុកិច្ច ។

## ១២ - ព្យាង្គតម្រួត

ពាក្យទាំងឡាយ មានពាក្យខ្លះកើតឡើងពីព្យាង្គរាយ ខ្លះពីព្យាង្គតម្រួត ។ ព្យាង្គតម្រួតកើតពីពាក្យពីរព្យាង្គជាធម្មតា, កាលណាព្យាង្គទាំងពីរនោះ ព្យាង្គខាងដើមមានអក្សរប្រកប ហើយអក្សរប្រកបនោះ ជាអក្សរនៅក្នុងវគ្គជាមួយគ្នា នឹងពាក្យព្យាង្គបន្ទាប់ ហើយព្យាង្គទាំងពីរ បើញែកគ្នាចេញព្យាង្គមួយៗគ្មានស័ព្ទប្រែ បើប្រែបានក៏ប្រែខុសសំដៅឆ្ងាយ ពាក្យថា: សន្ទូប, បណ្ដើរ.., បើញែកថា សន់-ទូប, បន់-ដើរ នោះពាក្យនិមួយៗឥតស័ព្ទថាជាអ្វីៗ នឹងតម្រួតពាក្យលុះតែអក្សរប្រកបរបស់ព្យាង្គដើម នឹងអក្សរព្យាង្គបន្ទាប់នៅត្រូវលំដាប់ផង គឺថាអក្សរទី ១ នៅលើទី ២, អក្សរទី ៣

នៅលើទី ៤, អក្សរទី ៥ នៅលើអក្សរទាំង ៤ ខាងដើមនៃវគ្គ ដូចពាក្យ ភិក្ខុ - ព្យគ្ឃ (ខ្លា) - អង្ករ - សង្ខារ - បង្គាប់ - សង្ឃឹម - បិញ្ចឹម - បញ្ឆិម មជ្ឈិម - ដណ្ដើម - គណ្ឋូប - កន្ដាំង ... ។



ឯអក្សរក្នុងពួកសេសវគ្គគឺ: យរលវ សហឡអ បើត្រូវពាក្យត្រួតនោះទឹងនៅក្រោមតួណាៗបាន ដូចពាក្យ: អង្វរ - ពន្យល់ - បន្ទ្រាក់ - បទ្វា - ពន្រៃ - បណ្ហា - បញ្ហា ... ។

---

## ១៣ - សម្លេងអក្សរ អឃោសៈ - ឃោសៈ

អក្សរដែលមានសម្លេងតឹងហៅថា អឃោសៈ អក្សរដែលមានសម្លេងធូរ ឬសំឡេងធំហៅថា ឃោសៈ ។ សញ្ញាដែលសំរាប់បន្ថែមលើតួព្យញ្ជនៈ ង ញ ប ម យ រ ល វ ស ហ ឡ អ ដើម្បីប្រើឲ្យគ្រប់គ្រាន់ក្នុងភាសា នោះកាលណាព្យាង្គពីរ ហើយព្យាង្គដើមមានស័ព្ទជាអឃោសៈ ឬជាឃោសៈ ព្យាង្គខាងចុងក៏នេសម្លេងទៅ

តាមព្យាង្គដើមមិនបាច់ថែមវណ្ណយុត្តិឡើយ ដូចពាក្យៈ សង្កាត-សម្-ប្រមាថ-សមា-ចម្បា-សាលា-កុមារ-ប្រវែង-ចម្ងាយ-សន្យា-សន្ទុត-សញ្ញា-ប្រាជ្ញា-វិហារ-ពាហាន-ជំហាន-ជំហារ... ។ តួព្យញ្ជនៈផ្សំដែលហៅថាផ្ញើជើងនោះ ជើងអក្សរដែលយកទៅផ្សំរនសម្លេងទៅតាមតួលើ តាមដោយស័ព្ទសម្លេងជា ឃោសៈ ឬ ជាអឃោសៈ មិនបាច់មានវណ្ណយុត្តិដូចគ្នា ។ ចូរមើលព្យញ្ជនៈផ្សំទាំងនេះ ក្ល គ្ល ខ្ល ឃ្ល ក្ន គ្ន ខ្ន ឃ្ន ឈ្ន ច្វ ជ្វ ប្វ ឆ្វ ខ្វ ខ្វ ខ្ញ ខ្ទ ស្ន ស្ទ ក្រ គ្រ ប្រ ប្រ ស្រ គ្រ ទ្រ ព្រ ម្រ... ក្នុង, កើតឃ្លង់, ក្នីគ្នា... ។

---

## ១៤ — នាមក្រិត - កិរិយាក្រិត

អក្សរជាគូនឹងគ្នាក្នុងវគ្គ · ពាក្យយារចេញពីពាក្យដើម ឬបែកចេញពីពាក្យដើមហៅថាកិតៈ ឬក្រិត ។ ដៅនៃពាក្យទាំងឡាយ សឹងបែកចេញទៅពីតួឯង ឬចេញទៅពីអក្សរជាគូដូចពាក្យៈ ឈ្មួញ បែកចេញទៅជាពាក្យ ជំនួញ, កោស ចេញ

 

ទៅជាខ្នោស, គាប ទៅជាឃ្នាប, ធី ទៅជាបំណី, ឆ្អិន ទៅជាចំអិន, ធ្ងន់ ទៅជាទម្ងន់, បួស ទៅជាផ្នួស, ពំនូន ទៅជាភ្នូន, គិត ទៅជាគំនិត, កាត់ ទៅជាកំណាត់, ទើបទៅជាទំនើប..។ លើកតែពាក្យខ្លះ ដែលវេយ្យាករណ៍ មានអធ្យាស្រ័យឲ្យប្រើដូចពាក្យៈ ដើរ ទៅជាថ្មើរ, ត្រង់ទៅជាដម្រង់ ឬតម្រង់, ត្រូវ ទៅជាតម្រូវឬដម្រូវ, ប្រដុំ ទៅជាក្ដុំ... កិរិយាដែលបែកទៅជានាម ហៅថាកិរិយាក្រិត ។ នាមដែលចេញមកពីកិរិយា ហៅថានាមក្រិតឬហៅថាកិតនាមក៏បាន ។ កិតនាមខ្លះជាកិរិយា ផាក់ជានាម

## ២៤–ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

 

ដូចពាក្យៈ អ្នកដើរ អ្នករែក អ្នកដេក អ្នកមក អ្នកបេះ អ្នកទៅ សឹងជាកត្តិនាម ។

ជំនុំនៃពាក្យ– ពាក្យដែលយើងនិយាយ កើតឡើងពីស័ព្ទច្រើនយ៉ាងៈ

១– នាម ។ ២– គុណនាម ។ ៣– កិរិយា ។ ៤– សព្វនាម ។ ៥– កិរិយាវិសេសន៍ ។ ៦– និបាត ។ ៧– ឧទានស័ព្ទ ។ ៨– បរិការស័ព្ទ ។



# ១៥ - នាម

សំដីដែលសំដែងនូវឈ្មោះ ជាគ្រឿងសំគាល់ឲ្យហៅបាន ដូចពាក្យថា: មនុស្ស-សត្វ-ដី-ទឹក-ខ្យល់-ឈើ-ទន្លេ-សមុទ្រ ។ល។ ពាក្យទាំងឡាយនេះហៅថានាម ។ នាមនាម មានពីរយ៉ាងគឺ: សាធារណនាម ១ អសាធារណនាម ១ ។

## សាធារណនាម

វត្ថុទាំងឡាយ ដែលមានបែបសណ្ឋានណាំគ្នាប្រហែលគ្នា ជាសាធារណនាម ដូចពាក្យហៅថា "ផ្ទះ" វត្ថុឯណាដែលមានភាព បែបប្រហែលនឹង



គេហៅស្ថាននោះហៅថាផ្ទះដូចគ្នា ៗ "ស្រែ" ត្រូវណាមានភាពដូចដី



នោះហៅថាស្រែដូចគ្នា ៗ "ឆ្កែ" សត្វឯណា មានភាពដូចគ្នាហៅថា ឆ្កែ ៗ "ដើមតាំង" ត្រូវមានភាពដូចដើមមានោះ ហៅថាដើមតាំង.. ៗ

ពាក្យហៅថា ផ្ទះ-ស្រែ-ឆ្កែ-ដើមតាំង ជាសាធារណនាម ។

## អសាធារណនាម

នាមឲ្យសំរាប់តែមនុស្សម្នាក់ សត្វមួយ ឬវត្ថុមួយជាក់ម្នាក់ឯង ហៅថាអសាធារណនាមព្រោះនាមនោះមិនចំពោះទូទៅឡើយ ដូចនាមថា: ភ្នំពេញ - មេគង្គ - ក្របេះ - ស៊ីសុវត្ថិ - នពេត្តម . . . ឈ្មោះភ្នំពេញសំរាប់តែក្រុងខ្មែរម្នាក់ឯង, ឈ្មោះមេគង្គសំរាប់តែទន្លេ នៅស្រុកខ្មែរនេះ, ឈ្មោះស៊ីសុវត្ថិ-នពេត្តម សំរាប់តែរូបស្ដេចដែលសុគតហើយនោះ ។

## ១៦- លិង្គរបស់នាម

នាមនាមទាំងឡាយមានភេទផ្សេងគ្នា ភេទរបស់នាមនោះ ហៅថាលិង្គ ។ លិង្គមាន ៣ យ៉ាងគឺ: បុំលិង្គ (ប៉ុងលឹង), ឥត្ថីលិង្គ, នបុំសកលិង្គ ។ បុំលិង្គគឺភេទសំរាប់មនុស្សប្រុស សត្វឬវត្ថុឈ្មោល, ឥត្ថីលិង្គ គឺភេទសំរាប់សំគាល់មនុស្សស្រី សត្វឬវត្ថុញី, នបុំស-កលិង្គជាភេទសំគាល់មនុស្ស សត្វឬវត្ថុខ្ទើយ គឺភេទមិនមែនជាប្រុសឬជាស្រី ជាឈ្មោលឬញី ។ តាមដោយបញ្ញត្តិនៃក្បួនហោក នាមរស់មនុស្សប្រុស ងាររបស់មន្ត្រីសឹងជាបុំលិង្គ ។ នាមរបស់មនុស្សស្រី នាមរបស់ ស្រុក - ភូមិ - នគរ - វត្ត - ខេត្ត - សឹងជាឥត្ថីលិង្គ ។ នាមរបស់មនុស្សខ្ទើយជានបុំសកលិង្គ ។ ឯក្នុងក្បួនខ្លះ វត្ថុដែលជាគ្រឿងលេងសឹងជាឥត្ថីលិង្គ ដូចអង្គញ់ - មេប្រឹក... ។

លិង្គប្រើជាពាក្យសំរាប់ប្រុសស្រី ដូចពាក្យថា: មា - ឪ - តា - ពូ - ធំ - អយ្យកោ - បិតុលា - កុមារ - យក្ស - យក្ខ - ចោរ - ភគី - ភាគិន - ភិក្ខុ - សាមណេរ - តោ - ពានរ..., ជាពាក្យសំរាប់បុំលិង្គ ។ ដូចពាក្យ

ហៅថា មីង - ម៉ែ - យាយ - អយ្យិកា - មាតុច្ឆា - កុមារី - យក្សិណី, (យក្ខិនី) - ចោរី - ភគិនី - ភិក្ខុនី - ភិក្សុណី - សាមណេរី - តារី - ពានរី ព្រាហ្មណី... ជាពាក្យសំរាប់ឥត្ថីលិង្គ ។

## ១៧ - វចនៈ

វចនៈ ជាពាក្យសំគាល់វត្ថុតែមួយ ឬវត្ថុច្រើន ។ ពាក្យដែលតំណាងវត្ថុតែមួយហៅថាវចនៈ ។ ពាក្យដែលតំណាងរបស់



ច្រើនហៅថាពហុវចនៈ ។ ក្នុងវចនៈទាំងពីរយ៉ាងមិនជាការសំខាន់ពេកទេ, កាលណាគេចង់ប្រើជាពហុវចនៈ គេផ្ទួនពាក្យ ឬគេថែមពាក្យទៀតដូចជា: ប្រុស ៗ ស្រី ៗ ក្មេង ៗ កូនទាំងឡាយ ឈើទាំងឡាយ អស់ទាំងសត្វ ។ តែមានពាក្យខ្លះដែលចេញពីបាលី ឬ សំស្ក្រឹត មានសំគាល់វចនៈខ្លះដែរ ដូចពាក្យថា: រុក្ខ - រុក្ខា, យក្ស - យក្សា ... រុក្ខ (ឯកវចនៈ), រុក្ខា (ពហុវចនៈ), យក្ស (ឯក) យក្សា (ពហុ.) ។

## ១៨ – គុណនាម

ពាក្យដែលសំដែងលក្ខណៈរបស់នាម ឬធ្វើនាមឲ្យមានបទ ដូចពាក្យថាៈ ថ្មរឹង - មនុស្សចាស់ - ដែកស្អិត - កៅស្រួយ ... រីឯ ចាស់ ស្អិត ស្រួយ ប្រាប់លក្ខណៈ ថ្ម - មនុស្ស - ដែក - កៅ ហៅថា គុណនាម ។ នាមនាមមាន លក្ខណៈសម្រេចហើយហៅថា



គុណបទ ។ គុណនាមមានបីយ៉ាងគឺៈ បកតិគុណនាម ១, វិសេសគុណនាម ១, អតិវិសេសគុណនាម ១ ។

## បកតិគុណនាម

គុណនាមសំដែងលក្ខណៈតាមលំអានជាប្រក្រតី ដូចពាក្យថាៈ ភ្នំធំ - ទន្លេវែង - ស្លឹកស្ដើង - វង់មូល - ដីខ្ពស់ - សេះធាត់ - សំពត់ម៉ដ្ឋ ស្រមោចតូច - អាវខ្លី - ក្ដារក្រាស់ - ប្រាក់រៀលសំប៉ែត - ក្មេងទាប គោស្គម - មនុស្សកំសោយ - ជាងប្រសប់ - កប៉ាល់លឿន - សក់ស្កូវ -

ផ្ទុំ - ខ្នុរស្រែគាល - ប្រាំងហោត - ភ្លើងក្ដៅ - ទឹកត្រជាក់ - ខ្យល់រងា- ត្បូងភ្លឺ - គុរលោង ឆ្កែកាច ... ។

## វិសេសគុណនាម



គុណនាមដែលសំដែងលក្ខណៈ របស់នាមឲ្យវិសេសឡើង ដូចពាក្យថា: ផ្លូវត្រង់ជាង - ឆ្កែនេះកាចជាង - គោនេះធំជាង - មនុស្សប្រសប់ជាង - កាំបិតមុតជាង - ឈើខ្ពស់ប្លែក ... ។

## អតិវិសេសគុណនាម

គុណកនាមដែលសំដែងលក្ខណៈឲ្យវិសេសបំផុត ដូចពាក្យថា: ស័ង្ខសផង់ - កំបោរសក្បុស - ស្បែកខ្មៅយង់ - កាំបិតមុតណាស់- គោយឺតណាស់ - កូនឧស្សាហ៍ណាស់ ... ។

# ១៩ - កិរិយាស័ព្ទ ឬកិរិយា

ពាក្យពោលនូវអំពើធ្វើ ឬពោលនូវដំណើរជាអ្វី ហៅថា កិរិយាស័ព្ទ ដូចពាក្យថា: ដើរ - ឈរ - អង្គុយ - ដេក - ស៊ី - ផឹក - ងូត - លាង - និយាយ - ស្ដី - ហៅ - យំ - ស្រែក - វាយ - ដំ - ដក - គាស់ - ឈូស - ចាំង - ភ្ជួរ - រាស់ - កាប់ - កាត់ - អាន - សរសេរ - តែង - ធ្វើ...



ពាក្យជាកិរិយាស័ព្ទ មានប្រធានកាលណា គេចងជាប្រយោគដូចពាក្យថា: ខ្ញុំដើរ... ខ្ញុំជាប្រធានរបស់កិរិយាដើរ ។ យើងដេក - គេឈូស - វាធ្វើ - កូនសិស្សសរសេរ - អ្នកស្រែភ្ជួរ... ។ កិរិយាមានពីរយ៉ាង គឺ: សកម្មកិរិយា ១, អកម្មកិរិយា ១ ។

## សកម្មកិរិយា

គេហៅថាកម្មគឺពាក្យដែលប្រើសំរាប់បំពេញអំពើរបស់កិរិយា គេហៅថាសកម្មកិរិយា គឺកិរិយាដែលត្រូវមានពាក្យមកបំពេញអំពើទើប

# ៣២–ប្ញក៏ ឋញ្ញឹដ្ឋាន និង ទុក្ខមដ្ឋាន



គ្រប់គ្រាន់ដូចពាក្យថា៖ ខ្ញុំឈូសឈើ, គេទិញសំពត់, អ្នកនេសាទស្ទូចត្រី, ចោរលួចទ្រព្យ... ។ ឈើ-សំពត់-ត្រី-ទ្រព្យ ជាកម្មរបស់កិរិយា ឈូស-ទិញ-ស្ទូច-លួច ។

## អកម្មកិរិយា

កិរិយាដែលមានអំពើគ្រប់គ្រាន់នឹងខ្លួនឯងហើយ ហៅថា អកម្មកិរិយា ដូចពាក្យថា៖ ខ្ញុំកើត, យើងទៅ, វាស្លាប់, កប៉ាល់ចេញ, ក្មើខ្ញុំមក, ប្អូនខ្ញុំដល់, ឈើឆាប់, សត្វហើរ, គេឈរ, ទឹកហូរ, គោបោល,



ឆ្កែលូ, គោរោទ៍, ព្រាបថ្ងូរ, ខ្លាគ្រហឹម, សំពត់ជ្រុះ, លោកមានប្រសាសន៍... ។

កិរិយាមានឈ្មោះហៅថា ហេតុកិរិយា គឺកិរិយាដែលធ្វើអំពើទៅគេ ដូចពាក្យថា៖ បង្រៀន គឺធ្វើអំពើទៅគេ ។

កិរិយាហៅថាសុទ្ធកិរិយា គឺកិរិយាដែលធ្វើចំពោះខ្លួនឯង ដូចពាក្យថា: រៀន គឺធ្វើអំពើចំពោះខ្លួនឯង ។

## ២០ - វិធីហាត់

ពាក្យមានបន្តក់ – កង់ កត់ កប់ ខ្វល់ ទល់ សក់ យល់ ពន់ ទក់ ផន់ បត់ បង់ ចង់ ហត់ ព្រនង់ កំពង់ ពន្យល់ ទំនប់ កញ្ចក់ បង្កង់ ដំទង់ គំរប់ ទំរង់ ចំណង់ កង្វល់ បង្អស់ បន្តក់ បំរត់ បន្ទប់ សំណល់ កញ្ឆក់ កាត់ ខាត់ សាត់ ចាត់ ផាត់ រាត់ ហាត់ ឃាត់ ណាត់ បង្ហាត់ បំបាត់ សំខាន់ សម្លាប់ សំគាល់ កំណាញ់ បន្ទាល់ ភ្ជាល់ ទំនាស់ ប្រញាប់ប្រញាល់ កន្ដាល់ អឺរ៉ាន់ រហាត់ ចំឡាក់ ស្រពន់ ប្រញាប់ ណាស់ កំចាត់កំចាយ ។

ពាក្យឥតបន្តក់ – កល កុសល ផល គន្ធ គណ បក្ក ឆត្ត គជទន្ត ជនបទ ជប ថលបថ កម្មបថ ថលយាន ខណ្ឌា បព្វជា បញ្ញាត្ត បព្វតរាជ និមិល ពលកាយ ភក្ត្រ កត្តកាល

កាលបក្ស ប្រាកដ ប្រយ័ត្ន ប្រភព បក្ខគណនា មណ្ឌល កមល មាណព រក្ខ រក្ស ក្សត្រ ហរិរក្ស ។

## ២១ - សព្វនាម

សព្វនាមជាពាក្យតំណាងនាម ដូចពាក្យថា៖ ខ្ញុំ, អ្នក, ឯង, វា, គេ, នាង, លោក, ព្រះអង្គ ... ជាសព្វនាម ។ សព្វនាមមានពីរយ៉ាងគឺ បុរិសសព្វនាម ១, វិសេសនសព្វនាម ១ ។

### បុរិសសព្វនាម

បុរិសសព្វនាមចែកជា៖ បឋមបុរិសៈ, មជ្ឈិមបុរិសៈ, ឧត្តមបុរិសៈ ។ បឋមបុរិសៈគឺ៖ វា, គាត់, គេ, នាង, លោក, ព្រះអង្គ ... ។ មជ្ឈិមបុរិសៈគឺជាសព្វនាមសំរាប់ប្រើជំនួសឈ្មោះបុគ្គល ដែលគេកំពុងតែនិយាយទៅរកក្នុងទីចំពោះមុខ ហើយនិយាយមិនចេញឈ្មោះឡើយ យកស័ព្ទនេះជំនួស ដូចពាក្យចំពោះមុខ៖ ឯង, លោក, អ្នក, នាង, អា, ហង ... តាមពាក្យទាប-ខ្ពស់-កណ្ដាល ។ ឧត្តមបុរិសៈគឺ៖ ខ្ញុំ, ខ្ញុំបាទ, ខ្ញុំឯង, អញ, អញខ្ញុំ, អាត្មាភាព, យើងខ្ញុំ,

យើង ... តាមពាក្យតាម-ខ្ពស់-កណ្ដាល ។ ឧទាហរណ៍ៈ កូនខ្ញុំបាន
ាយុ ... ដីនក្ដីបន្តិចហើយ ឥឡូវនេះវាទៅរៀនឯសាលា ។ មារបស់
ខ្ញុំនៅភូមិឯស្រុកស្រែ គាត់បានទទួលដំណឹងមកថាៈ គាត់នឹងមកលេង
នឹងខ្ញុំនៅថ្ងៃខាននស្អែក ។



សត្វពាហនៈគឺ : គោ-
ក្របី-ដំរី-សេះ, សត្វ
ទាំងនោះធ្វើប្រយោជន៍
ឲ្យយើង ប្ដូរយើងថែទាំវាឲ្យល្អ ។ ទេវីម្នាក់ឈ្មោះបទុមកេសរ វាគ
ចេញពីនគរជាមួយនឹងស្វាមីទៅដល់កណ្ដាលព្រៃ នាងក៏ប្រសូតបុត្រ



ហ្វូងយានមកប្រជាប់គុង
បុណ្យនេះ ទ្រង់នឹងយាន
មកដោយ យានសិវិកា,
នាម៉ឺនសព្វមុខមន្ត្រីនៅ
រង់ចាំថ្វាយបង្គំ
ព្រះអង្គ ។ អ្នកអញ្ជើញទៅកំពត នោះអ្នកនឹងទៅដោយអ្វីហ្ន៎ ! ។

កាលណាឯងទៅនៅទីក្រុង ឯងកុំដើរលេងយប់ ឯងកុំមានកៀន នឹងមនុស្សអាក្រក់ ។ អាឯងឈ្មោះអ្វី ? អាដែលលួចគេប៉ុន្មានដងហើយ ? អាឯងមានប្រពន្ធកូនឬទេ ? ។ នៅថ្ងៃទំនេរពីថ្ងៃរៀន, ខ្ញុំឆ្លៀតទៅសួរឪពុកម្តាយរបស់ខ្ញុំ ។ ល្ងាចនេះគេនិមន្តអាត្មាភាពទៅទេសនា ។ យើងរាល់រូប តែងតែមានសេចក្តីស្ងាប់ជាធម្មតានឹងជៀសពុំបាន ។

## វិសេសនសព្វនាម

វិសេសនសព្វនាម គឺជាស័ព្ទសំរាប់ប្រើជាជំនួយនាមនាមមានលំនាំជាបទវិសេសនៈ ដើម្បីនឹងមិនឲ្យប្រឡំសេចក្តីក្នុងសង្កាត់នៃប្រយោគមួយៗ ។ វិសេសនសព្វនាម មានពីរយ៉ាងគឺៈ វិសេសន-សព្វនាមនិយម១, វិសេសនសព្វនាមអនិយម១ ។ វិសេសនសព្វនាមដែលសំដែងសេចក្តីដាច់ស្រេចហៅថានិយម ។ វិសេសនសព្វនាមដែលសំដែងសេចក្តីមិនដាច់ស្រេចហៅថាអនិយម ។

វិសេសនសព្វនាមនិយមៈ នោះ, នុ៎ះ, ហ្នឹង, នេះ, ម្នាក់, មួយទៀត, ឯនេះ, ឯណោះ (Pronom démonstratif) ។

វិសេសនាមសព្វនាមអនិយមៈ ឯណា, ដទៃ; ណាមួយ, ផ្សេង, ទៀត, ដូចម្ដេច, ពួកខ្លះ, អ្នកខ្លះ, ខ្លះ, ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, អ្នកណា, អ្វី, ឯទៀត ( Pronom indéfini ) ។

វចនសព្វនាមឯកវចនបឋមបុរសៈ វា, គេ, នាង, លោក, ព្រះអង្គ, គាត់, ទេ ... ។ ពហុវចនបឋមបុរសៈ វាទាំងឡាយ, គេទាំងឡាយ, អស់នាង, អស់លោក ... ។

ឯកវចនមជ្ឈិមបុរសសព្វនាមៈ អ្នក, នាង, លោក, ឯង, គាត់, ហាង ... ។

ពហុវចនមជ្ឈិមបុរសសព្វនាមៈ អស់អ្នក, អស់នាង, អស់លោក, ឯងទាំងអស់គ្នា, គាត់ទាំងឡាយ ... ។

វចនឧត្តមបុរសសព្វនាមៈ ខ្ញុំ ( ឯក. ), យើង ( ពហុ. ), យើងខ្ញុំ ( ពហុ. ) ។

វិសេសនសព្វនាមក៏មានវចនៈដូចពាក្យថាៈ នេះ ( ឯក. ), នោះៗ (ពហុ.), ណា (ឯក.), ណាៗ (ពហុ.), ម្នាក់ៗ (ពហុ.) ។

## ២២ – កិរិយាវិសេសន៍

កិរិយាវិសេសន៍ជាសព្ទបន្ថែមលើកិរិយា ដើម្បីឲ្យកិរិយាមានសព្ទវិសេសឡើង ឬប្លែកឡើងទៀត ។ កិរិយាវិសេសន៍បន្ថែមសព្ទរបស់គុណនាមឲ្យប្លែកឡើងដែរ ដូចបានអធិប្បាយរួចហើយនៅខាងលើអំពីអតិវិសេសគុណនាមនេះឯង ។ បើកាលណាគេញែកពាក្យក្នុងបទសម្ពន្ធនោះគុណនាមនឹងកិរិយាវិសេសន៍បង្គាប់គ្នាជាបទហើយហៅថាអតិវិសេសគុណនាមក៏បាន ឬហៅញែកពីគ្នាចេញក៏បាន ។

កិរិយាវិសេសន៍ទាំងឡាយគឺ ឆាប់, ណាស់, យឺត, លឿន, មួយៗ, រឿយៗ, ទន្ទើន, ណឹមណុម, ឋិតថេរ, ស្ទូវ, រ៉ះ; ក្តុត, ភ្លាម, ថ្ងៃ, តាន់តាប់, ខ្ជាន់ខ្ជាប់, ញើបៗ, លបៗ, ណោះណោះ, តតាក់តតាំ, នឹង, នែលនល, ដរាប, នៅ, បណ្តាប់, បន្តោក, បន្តុប, បន្តិច, បន្ថែម; ប៉ោបៗ, ប៉ុក, ប្រកិត ប្រកឹង, គូង, ប្រូស, ព្រួត, ព្រាងើយ; រម៉ាំងរមោក, គ្រេង, ប្រូង, ព្រឹស, ប៉ុង, គ្រាំង, តឹង... ។

ឧទាហរណ៍ៈ ទៅឆាប់, មកភ្លាម, ដើរយឺត, មើលខ្ទាន់ខ្ទាប់, ធ្វើមារយាទប្រឹមប្រិយ, មានជីវិតឋិតថេរ, ដេញប្រកិត, ប្រកឹងទារ, ជួលគូង, ទៅរមាំងរម៉ោក, រលំគ្រែង, ទៅណេះ, ទៅណោះ, មកជពប, ជម្ងឺពុំទាន់ជានៅឡើយ, និយាយប៉ោចៗ, ដាក់ប៉ុក, រៀបបន្ទុប, អ្នកទិញមកថ្លៃបន្តិចហើយ, ជិះរត់លឿនស្ទើរ ... ។

## ២៣-វិធីប្រើអាយតនិបាត

អាយតនិបាត មានអត្ថប្រព្រឹត្តទៅតាមទំនងសេចក្ដី ដូចមានតទៅ ៖

អាយតនិបាតទី ១ – "រឺ" សំរាប់ប្រើជាបទប្រធានឬដើមបទ ឧ. រឺបុណ្យទឹងបាប អំពើសុភាព នោះរាំតែងតាម... ។ រឺគ្រូបាធ្យាយ ប្រដូចនូវម្ដាយ អាពុកឯងហោង ។ រឺអំពើជាកុសល ជនគប្បីធ្វើ ។

អាយតនិបាតទី ២– មានអត្ថ ៥ យ៉ាង:

១– "ឲ្យ" សំរាប់ភ្ជាប់កម្មរបស់កិរិយាសកម្ម ។

## ៤០–ធ្នាក់ មជ្ឈិមជ្ជន និង ឧត្តមជ្ជន

ឧទាហរណ៍ៈ គេស្តាប់នូវធម៌, សង្ឃសំដែងនូវធម៌ ។ ប៉ុន្តែក្នុងភាសាដែលគេនិយាយជាធម្មតា គេច្រើនកាត់ពាក្យ "នូវ" ដូចគេនិយាយថាៈ គេស្តាប់ធម៌, លោកសំដែងធម៌ ។

២– "កាន់" សំពប់ក្អាប់កម្មទៅកិរិយាអកម្ម ឧ: គេទៅកាន់ផ្ទះ, វាមកកាន់ផ្ទះ ។ ប៉ុន្តែតាមភាសាធម្មតាគេ ច្រើននិយាយកាត់បចេដូចជា: ខ្ញុំទៅផ្ទះ, គេមកផ្ទះ ។

៣– "ញុំាង" ជាទទួលសម្រេចនូវអំពើដែលគេឲ្យធ្វើ, ឧ. ពពួកសត្វផង សាហាវយង់ឃ្នង ប្រយ័ត្នញុំាងបាន . . ; ព្រះពុទ្ធត្រាស់ដឹងនូវអរិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង, គ្រូបង្រៀនខ្ញុំបានសិស្សញុំាងសិស្សឲ្យរៀន ។

៤– "អស់" ប្រព្រឹត្តទៅ រហូតដល់, ឧ. គេទៅអស់រយាជន៍បី, គេទៅអស់យប់មួយ ។

៥– "នឹង" ឬ "បំពោះ" ទទួលពាក្យដែលគេនិយាយបំពោះខ្លួន, ឧ. ខ្ញុំបាននិយាយនឹងអ្នក, - បំពោះអ្នក, គេថ្កោមតនឹងខ្ញុំ ។

## អាយតនិបាតទី ៣– មានអត្ថ ៦ យ៉ាង:

១– "ដោយ" ជាគ្រឿងសម្រេចនូវអំពើ ។. គេធ្វើនូវអំពើដោយកាយ ។ គេកាន់អ្វីៗ ដោយដៃ ។

២– "ដោយផ្លូវ" ឬ "តាម" ឬ "ដោយសារ" ជាផ្លូវជាលំនាំដែលប្លែកពីការសម្រេចនូវអំពើ ។. ព្រះពុទ្ធរុងរឿងដោយនូវតេជះ, ចូរធ្វើតាមពាក្យនៃអញ, វារស់នៅដោយសារសេចក្ដីទំនុកបំរុងនៃខ្ញុំ ។

៣– "គឺ" ឬ "ដែល" ជាអ្នកសម្រេចនូវអំពើអំពីខ្លួនឯង ។. ធម៌គឺភាវៈដែលទ្រទ្រង់, ពាក្យនេះដែលខ្ញុំបានប្រាប់ហើយ, គឺអ្នកឯងមិនត្រូវធ្វើយ៉ាងនេះទៀត, ព្រះសាស្ដា គឺអ្នកទាំងឡាយគប្បីឲ្យអត់ទោស ។

៤– "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ជាហេតុ, ជាទំនង, ជាដំណើរ ។. បានជាគាត់នៅក្នុងទីនោះ ព្រោះតែសក្ការៈ, សត្វលោកមានចិត្តខ្ពស់ឡើងព្រោះលាភ មានចិត្តទ្រោមចុះព្រោះខាតលាភ ។

៥ — "មាន" ជាអាការៈ ឧ. បើបុគ្គល មានចិត្តគិតទោស ប្រទូស្តហើយ ពោលក្តី ធ្វើក្តី... ។

៦ — "ដោយ" ប្រកបជាមួយ ឧ. ចូរព្រមព្រៀងមួយអន្លើ ដោយដំណើរនោះ ។

## អាយតនិបាតទី ៤ — មានអត្ថ ៣ យ៉ាង:

១ — "ដល់" ជាទីទទួលនូវអំណោយ ឧ. ទាយកឲ្យនូវទាន ដល់សង្ឃ, ក្រលំបាកឲ្យផល ដល់អ្នកកំដល ។

២ — "ដើម្បី" ឬ "បំរុង" ជាទីធ្វើ·បញ្ញាន ឧ: គេបង្គាប់មនុស្សឲ្យក្រាលនូវអាសនៈទាំងឡាយ ដើម្បី ឬ បំរុងភិក្ខុសង្ឃ, អាពុកធ្វើទៅនូវសំលៀកបំពាក់ទាំងឡាយ ដើម្បីកូន ។

៣ — "ចំពោះ" ឬ "នឹង" ជាទីត្រូវគេបៀតបៀន ឧ. អ្នកណាប្រទូស្ត ចំពោះ ឬ នឹងមនុស្សដែលមិនប្រទូស្ត ។

## អាយតនិបាតទី ៥ — មានអត្ថ ៣ យ៉ាង:

១ — "អំពី" ឬ "ចាក" ឧ. ភ័យ អំពីសេចក្តីស្លាប់, បុគ្គលគប្បីឃាត់នូវចិត្ត ចាកបាប គឺថាបុគ្គលគប្បីលះបង់បាប ។

២ – "ជាង" ជាដែនប្រៀបធៀបឲ្យដឹងថាលើស ឬ ថយជាងគ្នា ។. សីលជាគុណជាត មានផលច្រើន ជាងទាន ។

៣– "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ជាទីមូលហេតុ-ដើមចម ។. សត្វទាំងឡាយកើតព្រម ព្រោះសេចក្តីល្ងង់នាំអាទ៍ឲ្យកើត ។

អាយតនិបាតទី ៦– មានអត្ថ ៥ យ៉ាង:

១ – "នៃ" ឬ "របស់" ជាគ្រឿងជាប់ដោយម្ចាស់របស់ ។. ផ្ទះ នៃអ្នកស្រែ ឬ របស់អ្នកស្រែ ។

២ – "នៃ" ជាគ្រឿងជាប់ដោយពួក-ដោយក្រុម ។. ប្រជុំ នៃជនទាំងឡាយ ហ្វូង នៃគោទាំងឡាយ ។

៣ – "នៃ" ជាគ្រឿងជាប់ដោយការសព្ទខាងដើម ។. ភារៈ នៃអត្ថ គឺកុលបុត្តគប្បីដឹងបានដោយកម្រ, គិច្ចដោយប្រទីបមិនបានឡើយ ព្រោះភារៈ នៃពន្លឺព្រះអាទិត្យមានក្នុងកាលឥឡូវនេះ ។

៨– "កាល" ឬ "កាលបើ" ឬ "កាលដែល" ជាសេចក្ដីជ្រែកចូលមកប្រហែលដូចជាបទប្រធានៈដោយឡែក ។: កាលដែលទារកកំពុងយំ បិតាចេញទៅហើយ, អ្នកទាំងឡាយចូររង់ចាំក្នុងទីនុះបន្តិចសិន, កាលបើខ្ញុំនិយាយថា: អ្នកទាំងឡាយចូរចូលមកចុះ ចូរមកឲ្យឆាប់ ។

៩– "ជំនុំ" ឬ "បណ្ដា" ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួម ដែលប្រមូល ។. បណ្ដាមនុស្សទាំងឡាយ ក្សត្រិយ៍ក្លៀវក្លាបំផុត ។

អាយតនិបាតទី ៣ – មានអត្ថ ៩ យ៉ាង:

១– "ក្នុង" ជាទីកំបាំង ។. គេអង្គុយក្នុងខាងក្នុងនៃបន្ទប់ ។

២– "ក្នុង" ជាទីជ្រែកជ្រាប ឬ លាយគ្នា ។. ប្រេងស្អិតនៅក្នុងល្ងទាំងឡាយ, ទឹកដោះស្រស់ស្អិតនៅក្នុងទឹក ។

៣– "ក្នុង" ជាទីអាស្រ័យ ។ ត្រីទាំងឡាយនៅក្នុងទឹក ។

៤– "ក្នុង" ជាកាល ជាពេល ។. កុសលចិត្ត ជាចិត្តកើតឡើងហើយមានក្នុងសម័យឯណា ។

៥– "លើ" ឬ "ក្នុង" ឬ "ត្រង់" ឬ "នា" ជាទីរង-ទ្រ-ផ្ទាប់-ជ្រៀតជ្រែក ។. ព្រះដ៏មានព្រះភាគគង់ហើយលើអាកាសដែលគេក្រាលហើយ, រោមទាំងឡាយឮដ៏ទ្រូង ឬ ត្រង់ទ្រូង ។

៦– "នាកាល" ឬ "កាលបើ" ឬ "កាលដែល" ជាសេចក្ដីដែលតូលប្រហែលដូចជាបទប្រធាន ។. នាកាលព្រះអាទិត្យអស្ដង្គតហើយ ព្រះចន្ទរះឡើង, កាលបើយ៉ាងនេះមាន មានតែយើងកុំទៅ, កាលដែលមាណពនោះនិយាយច្រើន ៗ ទៅ សរីរៈទាំងអស់នៃព្រាហ្មណ៍ ពេញផ្សព្វផ្សាយហើយដោយបីតិ ។

៧– "និមិត្ត" ជាគ្រឿងចំណាំ-ជាហេតុ ។. ដំរី នឹងគេសម្លាប់ និមិត្តភ្លុក (ព្រោះភ្លុក-ព្រោះតែភ្លុក) ។

៨– "ជំនុំ" ឬ "បណ្ដុំ" ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួមដែលប្រមូលគ្នា ។. ជំនុំឬបណ្ដុំភិក្ខុទាំងឡាយពីររូបនោះ ភិក្ខុមួយរូបដល់ហើយនូវសោតាបត្តិផល ។

៩– "ជិត" ឬ "ទៀប" ជាទីជិត-ប្រែប ឧ. ស្រុកទាំងយើងជិតក្រុង ឬ ទៀបក្រុង, ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី ។

អាលបនៈ – អាលបនៈ ជាពាក្យសម្រាប់ប្រើជាសំដីស្រែកហៅ ឬ ពោលចំពោះ មានអាការៈដូចស្រែកហៅ ដូចពាក្យថា: "បពិត្រ, ម្នាល, នែ, ហៃ" តាមសេចក្ដីគោរព ឬ ពាក្យគោរព ឧ. បពិត្រមហាពជ សូមព្រះអង្គចំរើនទ្រង់ឈ្នះ, ម្នាល ឬ នែកូនចូរកុំទៅ...: ។

## ២៤-- និបាតស័ព្ទ

និបាតជាស័ព្ទសំរាប់ផ្សំសំដីត្រង់ឃ្លាល្បះមួយៗ ជាជំនួយនាមស័ព្ទនឹងកិរិយាស័ព្ទ ឲ្យមានសេចក្ដីស្រឡះ ច្បាស់លាស់ពិរោះស្រួលស្ដាប់ ដូចពាក្យថា: ក៏-ក៏ដោយ-ក៏ដែរ-ដែរ-ផង-ឯ-បើ-តោះ-តោះបី-បើទុកជា-ទើប-ពុំនោះសោត-ឈល-ល្អឹកតែ-ព្រោះ-ផ្សិត ជាដើម ។ និបាតសំ

មានច្រើនយ៉ាងគឺ: អាយតនិបាតជាស័ព្ទសំរាប់ចងក្រងពាក្យ ដែលជាកម្មរបស់កិរិយា ឬ ជាពាក្យបំពេញបទរបស់នាមនាម ដូចពាក្យថា: ខ្ញុំស្តាប់នូវពាក្យ, វាទៅកាន់ផ្ទះ, កូនរបស់ខ្ញុំ, ភូមិផង, យើង ... : ពាក្យ: នូវ, កាន់, របស់, នៃ... ជាអាយតនិបាត ។

អាយតនិបាតទាំងឡាយគឺ: រី, នូវ, កាន់, អស់, ញុំាង, ចំពោះ, ដោយ, គឺ, ហេតុ, ព្រោះ, ដល់, បំរុង, អំពី, របស់, នៃ, កាលបើ, ទៀប, ជិត, និមិត្ត ។ (ដូចមានពិស្តារក្នុងខាងលើ)

## និបាតប្រាប់កាល – ប្រាប់ពេល (កាលត្ថវាចកៈ)

គ្រានោះ, លំដាប់នោះ, ដងនោះ, កាលនោះ, ក្សណនោះ, ព្រឹក, អំពីព្រឹក, ថ្ងៃ, ក្នុងវេលាថ្ងៃ, ល្ងាច, វេលាល្ងាច, ម្សិល, ម្សិលមិញ, ពីម្សិលមិញ, ស្អែក, ខានស្អែក, ខានស្អែកមួយ, អម្បាញ់មិញ, ក្អាម, រំពេច, សិន, តទៅ, ក្នុងខាងមុខ ។ល។

## និបាតប្រាប់ទី (ឋានត្ថវាចកៈ)

ខាងលើ, ខាងក្រោម, ខាងក្រោយ, ខាងក្នុង, ខាងក្រៅ, ចន្លោះ, រវាង, ស្ងាត់, ទីស្ងាត់, កំបាំង, កំបាំងពីមុខ, ចំពោះមុខ, នៅមុខ,

ជាំង, ឯមុខ, ឯនាយ, ឯអាយ, ខាងនាយ, អាយ ។ល។

## និបាតប្រាប់សេចក្ដីប្រៀបប្រដូច (បរិច្ឆេទត្ថវាចកៈ)

ដូច, ដូចជា, បីដូច, ហាក់ដូច, ប្រដូច ប្រហែលដូច, យ៉ាងណា, យ៉ាងណាមិញ, យ៉ាងនេះ, យ៉ាងនោះ, ដូច្នេះ, ដូច្នោះ, ដូចម្ដេចមិញ ។ល។

## និបាតប្រាប់ប្រការ (បការត្ថវាចកៈ)

ម្ដេច, ដូចម្ដេច, ដោយប្រការដូចម្ដេច, ដោយប្រការនោះ ។ល។

## និបាតប្រាប់សេចក្ដីឃាត់ហាមជាប់ខាត (បដិសេធនត្ថវាចកៈ)

កុំ, ពុំ, មិន, ឥត, ខាន, ពិត, មែន, តែប៉ុណ្ណោះ, គ្រាន់តែ, មិនមែន, មែនពិត, វៀរលែង, វៀរលែងតែ, លើកលែងតែ, កុំឡើយ, ពុំឡើយ, លម្មហើយ ។ល។

## និបាតប្រាប់សេចក្ដីតាមបានឮ (អនុស្សវនត្ថវាចកៈ)

ឮថា, ម្ខាងឮថា, មានដំណាលថា ។ល។

## និបាតប្រាប់សេចក្ដីជញ្ជឹង-ប្រមើល-ស្មាន-ណាត់

(បរិកប្បត្ថវាចកៈ)

បើ, បើជា, ប្រសិនបើ, ទោះបី, លុះតែ, បើដូច្នោះ, ធ្វើដូច, ម្ដេចហ្ន៎ ។ល។

## និបាតប្រាប់សេចក្ដីសួរដំណឹង (បុច្ឆនត្ថវាចកៈ)

ឬ, ឬក៏, ឬអ្វី, ឬទេ, ដូចម្ដេច, ដែរឬ, យ៉ាងដូចម្ដេច, យ៉ាងណា, ទេដឹង, យ៉ាងណានេះ, អេះ, ហ៎, ហ្ន៎, ។ល។

## និបាតប្រាប់សេចក្ដីឆ្លើយ-ទទួល (សម្បដិច្ឆនត្ថវាចកៈ)

អើ, បាទ, ព្រះបាទ, ព្រះបាទម្ចាស់, ករុណា, ករុណាពិសេស, ចាះ, ចះ, ពរម្ចាស់, មែ, ព្រះមែម្ចាស់, ចំរើនពរ, ថ្វាយព្រះពរ ។ល។

## និបាតប្រាប់សេចក្ដីតឿន (ឧយ្យោជនត្ថវាចកៈ)

ហ៎, ដូចជាតឿន, ឆាប់ៗ ។ល។

## និបាតប្រាប់សេចក្ដីច្រើនយ៉ាង (អនេកត្ថវាចកៈ)

ក៏, ឯ, ដ្បិត, គឺ, ផង, មួយ, ខ្លះ, ឬ, ពិត, មែន, ដែរ, អើក៏, មែនពិត, ពីព្រោះ, ក៏ដោយ, ក៏បាន, ពុំនោះ-

សោតមួយវិញទៀត, ចំណែកខាង. ប៉ុន្តែ, ប៉ុន្តែថា, ឬបើ, ក្រែង, ដូចជា, ម្យ៉ាងទៀត ។ល។

## និបាតប្រាប់សេចក្ដីគ្រាន់តែបំពេញបទ (បទបូរណត្ថវាចកៈ)

ហ្ន, ហ៏, ហាៈ; យី, យើ, ឯង, ឌុ, យីអើ ។ល។

## និបាតប្រាប់សេចក្ដីផ្សេងៗ (នានត្ថវាចកៈ)

មែន, ខុស, ទេ, ទៀត, វិញ, ខ្ពស់, ទាប, ប្រាកដ, ដោយពិត, ១វិញទៀត, ក្រៃពេក, ក្រៃលែង, រឿយៗ, ញឹកញយ, ជាក់លាក់. ពីចម្ងាយ, ក៏មែនហើយ, សូម្បី, តិចតួច, ចាប់ដើម, តាំងពី, ពីដូច, កុហក, មួយគ្រា, ម្ដង, តិចៗ, សន្សឹម, សំរៀម, ថ្នមៗ, ញើបៗ, មួយរយជង, មួយអន្លើ, ជាមួយ, ខ្លួនឯង ។ល។

## និបាតប្រាប់សេចក្ដី (ជាអាលបនៈ)

សំរាប់អ្នកគ្មានគេជះ ទៅកាន់អ្នកមានគេជះ ឬអ្នកមានគេជះ ទៅកាន់អ្នកគ្មានគេជះ ។

អាលបនត្ថបក:) សូមព្រះតេជះ, សូមព្រះតេជះ ដំកល់លើត្បូង, បូមទ្រង់មេត្តាប្រោស, សូមទានមេត្តាប្រោស, ទានប្រោស, បពិត្រ ព្រះអង្គ, បពិត្រព្រះករុណា, បពិត្រលោកដ៏ចំរើន, នែនាយ, នះបៅ, ព្រះស្តែង, វុំ, វុំយ, នែអ្នកដ៏មានអាយុ, នែអ្នកដ៏ ចំរើន, អស់លោកទាំងឡាយ ៗ នាង អានាង..., ៗលៗ

## ឧទានសព្ទ

សព្ទសម្រាប់គ្រាប់សូរសំឡេង ឬជាសម្លេងភ្ញាក់មាត់ដោយ ភ្ញាក់ផ្អើល ព្រោះមានភ័យ ឬមានសេចក្តីត្រេកអរក្រៃពេក ៗ ក! ប៉ុង! គ្រាំង! ប្រិបៗ! ភឹង! វ៉ែកៗ! ប៉ាំង! ខ្ទូនខ្ទួន! ព្រុះទ្រា! គម្ម! ៗលៗ

## បរិវារសព្ទ

មានពាក្យខ្លះឥតស័ព្ទប្រែ សំរាប់តែបន្ថែមសំដី ពាក្យទាំង នោះហៅថាបរិវារសព្ទ ៗ ជាធម្មតា បរិវារស័ព្ទភ្ជាប់នឹងនាម នឹងគុណនាម មានលំនាំដូចគតិវិសេសគុណនាម ៗ ពាក្យ ទាំងនោះគឺ: ប្រអប់ប្រអូង, ចានក្បាន, ផ្ទះសម្បែង, សូស្តុក,

ចំណីចំណុក, ព្រៃផ្សៃ, គោអំពៃ, សេះអំពែះ, មនុស្សម្នា, ចិនព្រិន, យួនព្រួន, ម៉ូះម៉ា, ក្មេងក្មាង, ថ្នាំសង្កូវ, ស្មៅព្រៅ, ដំណាំដំណោច, សត្វពន្លាត់, ទំនែក, ឧស្សាហ៍អាសាញ់, ស្គុះស្គាយ, ស្គោកស្គាំង, ក្បូងក្បាត់, ដំបងព្រនង់ ។

## ២៥—សំខ្យា ឬ សំខ្យាស័ព្ទ

សព្ទសំរាប់រាប់នាមហៅថាសំខ្យាស័ព្ទ ។ សំខ្យាស័ព្ទមាន ពីរយ៉ាងគឺ បកតិសំខ្យា នឹងបូរណសំខ្យា ។

### បកតិសំខ្យា

សំខ្យា ដែលរាប់តាមប្រក្រតីឲ្យដឹងចំនួនរបស់នាមនាមថា ប៉ុណ្ណេះ ប៉ុណ្ណោះ ដូចរាប់ថា: មួយ - ពីរ - បី - បួន - ប្រាំជាដើម ហៅថាបកតិសំខ្យា ។

### បូរណសំខ្យា

សំខ្យាដែលរាប់នាមនាមបន្តប់ជាជាន់ៗ តាមលំដាប់តាមថ្នាក់ ដូចពាក្យថា ដំបូង(ទីមួយ)- គំរប់ពីរ - គំរប់បី - គំរប់បួន - គំរប់ប្រាំ

ជាដើមនឹងពាក្យថា: បឋម: - ទុតិយ: - ចតុត្ថ: - បញ្ចម: - ឆដ្ឋ: ហៅថាបូរណសំខ្យា ។

បកតិសំខ្យាមានពីរពួកគឺ: សំខ្យាសព្ទនាម១, សំខ្យាគុណនាម ១ ។ សំខ្យាសព្ទនាមមានបួនគឺ: មួយ - ពីរ - បី - បួន ។

សំខ្យាសព្ទតាំងពីប្រាំតទៅសឹងជាគុណនាមទាំងអស់ ។ ឯបូរណសំខ្យាជាគុណនាមទាំងអស់ដែរ ។

វិធីប្រើសំខ្យាសព្ទ — ទីងកប់វត្ថុ ១ គេដាក់សំខ្យារៀងភ្ជាប់ពីក្រោយនាមនាម ឬភ្ជាប់ខាងមុខនាមនាម តាមដោយទំនងស្រួលជាក្នុងភាសា ។ ដូចពាក្យថា ១ រៀល - ពីររៀល - មួយពាន់ម៉ែត្រ - មួយសែនហាប - មួយលានតោក... គោពីរ - សេះហុកសិប - ឥដ្ឋមួយម៉ឺន - ពាហានមួយកោដិ - ស្វាយប្រាំស្ទឹក ... កូនជម្រូង - ថ្នាក់បន្ទាប់ - សេចក្ដីគំរប់ប្រាំពីរ - បឋមដ្ឋាន - បឋមាសាឍ - ទុតិយវិដ្ឋា - បញ្ចមីទុរោសថ ។ល។



## ២៦ — បុព្វបទ

អ (សំរាប់បដិសេធ) សព្ទ „អ" ជាសព្ទសំរាប់បដិសេធ ។ "អ" បដិសេធនេះសំរាប់រៀងភ្ជាប់នឹងសព្ទដទៃ សេចក្ដីមានន័យថា: ពុំ-មិន-ឥត-មិនមែន ដូចពាក្យ: អកតញ្ញូ-អភ័ព្វ-អកុសល-អភ័យ-អទុក្ខ-អរោគ-អនត្ថា-អកម្ម-អគតិ-អគោចរ... ជាដើម ។ „អ" បដិសេធនេះប្រើជាបុព្វបទហៅថា "អ" បុព្វបទ ។ មានបុព្វបទពួកមួយទៀត សំរាប់រៀងភ្ជាប់ខាងដើមពាក្យ ។ បុព្វបទទាំងនោះមានន័យថា ឲ្យ... ធ្វើឲ្យ... ដូចពាក្យថា: កកាយ-បញ្ចូល-បណ្ដាញ-បង្វិល-បន្ទូរ-បន្ថយ-បន្ថែម-បណ្ដើរ-ទទាស់ទទែង-បង្ខូច-បំបោល-បញ្ឈប់-បង្រៀន:.. ជាដើម សឹងជាពាក្យជាប់ដោយបុព្វបទ ក បញ បណ បន ញ ទ បំបង... ។

## ២៧ -- អាគម

គេហៅថាអាគមគឺអក្សរចុះថែមត្រង់ចន្លោះដូចពាក្យថាៈចតុរង្គ-និរន្តរ-បរិយោសាន-ចតុរារិយសច្ច... ។ ចតុ-អង្គ ជាចតុរ-អង្គ ជាចតុរង្គ, និ-អន្តរ ជានិរ-អន្តរ ជានិរន្តរ, បរិ-ឧសាន ជាបរិយ-ឧសាន ជាបរិយោសាន, ចតុ-អរិយសច្ច ជាចតុរ-អរិយសច្ច ជាចតុរារិយសច្ច, អក្សរ រ-យ ដែលយកមកថែមដើម្បីសំរួលស័ព្ទអាន ហៅថា អាគម ។ អាគម សំរាប់ប្រើតែក្នុងភាសាបាលី និងភាសាសំស្ក្រឹត នោះអក្សរដែលយកមកប្រើជាអាគមមានចំនួនសំរេច ។

## ២៨-- ឧបសគ្គៈ

ឧបសគ្គ ជានិបាត ទឹងជាអព្យយស័ព្ទ (ពាក្យមិនផ្លាស់ប្តូររូបទឹងស័ព្ទ) ដូចជានិបាតនានាដែរ តែពួកនិបាតដែលហៅថា

# ៥៦ – ថ្នាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

ឧបសគ្គៈនោះ មានចំនួនតែ ២០ ស័ព្ទ ហើយមានរបៀបបែបផែនក្នុងវិធីបង្កើតពាក្យដោយឡែកផ្សេងពីនិបាតនានា ៗ ក្នុងការបង្កើតភ្ជាប់ពាក្យ គេដាក់ឧបសគ្គៈជាខាងដើមនាមស័ព្ទ និងកិរិយាស័ព្ទ ៗ

ឧបសគ្គៈទាំង ២១ ស័ព្ទគឺៈ

អតិ ប្រែថា កន្លង - ក្រៃ - ក្រៃពេក - ពេក...

អធិ – ក្រៃលែង - ក្រៃពេក - លើសលុប - លើសលែង - សង្កត់

អនុ – តាម - តូច - បន្ទាប់ - រង - ក្រោយ - បណ្ដោយ - លំដាប់

អប – ប្រាស - គេច - វៀស...

អបិ ឬ បិ – ជិត - ខាងលើ...

អភិ – ក្រៃពេក - ធំ - ចំពោះ - ឆ្ពោះ - ខាងមុខ...

អវ ឬ ឱ – ចុះ - ចុះក្រោម - ទាប - ស្រេច...

អា – ឲ្យទៅ - សព្វ - ក្រៃលែង...

ឧ – ឡើង - ខ្ពស់ - ក្រៅ...

ឧប – ជិត - ចូលទៅជិត - មាំ - ស៊ប់...

ទុ – អាក្រក់ - ក្រ - កម្រ - លំបាក...

និ ប្រែថា ចេញ-មិនសល់-មិនមាន-ឥត...

នី — ចេញ-ចូល-ចុះ...

ប — ខ្ពស់ទៅ-ខាងមុខ-ចេញមុខ...

បដិ-បតិ — បំពោះ-តប-ត-ប្រាស-ត្រឡប់...

បរ — ខាងមុខ...

បរិ — ជុំ-ជុំវិញ-គ្រប់គ្រាន់-ស្រេច...

វិ — ផ្សេង-ប្លែក-ច្បាស់-ជាក់-ប្រាកដ...

សំ — ព្រម-ជាមួយ-ល្អ-ប្រពៃ...

សុ — ងាយ-ស្រួល-ស្រណុក-ល្អ-ប្រពៃ-ណាស់-ម៉េះ...

ពាក្យដូចមានតទៅសឹងជាពាក្យមានឧបសគ្គៈ

បរិបូណ៌ ទុរគត(ទុគ្គត)បរាជ័យ-អនុគ្រោះ-អភិបាល-អធិការ-អវសាន-(បរិ-ឧសាន)បរិយោសាន-ឧបរាជ-និរភ័យ-អធិបតី-វិកាល-វិបរិត-សុវិជ្ជា-ទុវិជ្ជា-អបរាជ័យ-និរន្តរ-និរទោស-អធិជ័យ-អនុនាយក-អនុស្សាវនា-សុគតិ-សុគន្ធ-វិជ័យ-ទុព្ភិក្ខ...។

## ២៩ — សម្ពន្ធ

សម្ពន្ធជាគ្រឿងចងបទ ឬចងប្រយោគ ។ ដើម្បីភ្ជាប់ពាក្យចងជាបទក្នុងសង្កាត់មួយៗ ឬក្នុងប្រយោគមួយ ត្រូវឲ្យដឹងថាបទណាគួរចូលទៅរកបទណា តាមលំអានវេយ្យាករណ៍ ។

ឧទាហរណ៍ៈ ១ — " ឈ្មួញ ដឹក ស្រូវ "

ឈ្មួញ ៖ នាម, សាធារណៈ, ឯកវចនៈ, បឋមបុរសៈជាប្រធានរបស់កិរិយា ដឹក ។

ដឹក ៖ សកម្មកិរិយា, បច្ចុប្បន្នកាល, ឯក. ។

ស្រូវ ៖ នាម, សាធារណៈ កម្មរងអំពើ ដឹក ។

២ — " ស្ត្រីៗ ទូល បន្លែ ដោយ កញ្ជើ "



ស្ត្រីៗ, នាម, សាធា. ពហុ. បឋមបុរសៈ ជាប្រធានរបស់កិរិយា ទូល ។

ទូល : សកម្មកិរិយា, បច្ចុប្បន្នកាល, ពហុ. ។

បន្ទែ : នាម, សាធា. ពហុ. កម្មរងអំពើកិរិយា ទូល ។

ដោយ : អាយតនិបាត

កញ្ឆើ : នាម, សាធា. ឯក. អកម្មរងអំពើ ទូល ។

" បងខ្ញុំ សង់ ផ្ទះថ្មីមួយ នៅផ្លូវនរោត្តម "

បងខ្ញុំ : បទមជ្ឈលុប (កាត់បទពីបទរបស់ខ្ញុំ ឬបទនៃខ្ញុំ),

នាម, សាធា. ឯក. បឋមបុរិសៈ ជាប្រធានកិរិយា សង់ ។

សង់ : សកម្មកិរិយា, បច្ចុប្បន្នកាល, ឯក. ។

ផ្ទះ : នាម, សាធា. ឯកៈ កម្មរងអំពើ សង់ ។

ថ្មី : បកតិគុណនាម, ឯក. គុណបទរបស់ផ្ទះ ។

មួយ : សំខ្យាគុណនាម, ឯក. គុណបទរបស់ផ្ទះ ។

នៅ : និបាតប្រាប់ទី ។

ផ្លូវនរោត្តម នាមៈ អសាធា. ឯក. អកម្មរងអំពើ សង់ ។

## ៤ – "ឯង កុំដើរលេង ឡើយ"

ឯង : មជ្ឈិមបុរិសៈ (ម. បុ. ស៣) ប្រធាន ដើរលេង : ឯក. ។

ដើរលេង : អកម្មកិរិយា, ឯក. បច្ចុប្បន្នកាល ។

កុំឡើយ : និបាត បដិសេធ (បដិសេធនត្ថវាចកៈ)

## វិធីហាត់

១ – ចូរដាក់លិង្គទៅខាងមុខនាមនាមនិមួយៗ ។ ឧបមាដូច ប្រុស (បុំលិង្គ) ស្រី (ឥត្ថីលិង្គ)

| | | |
|---|---|---|
| ប្រុស ... | យក្ខ, យក្ស ... | រាជីនី ... |
| ស្រី ... | យក្សា ... | រាជិនី ... |
| ឪពុក ... | យក្ខិនី ... | ទេវី ... |
| ម្ដាយ ... | យក្សិណី ... | ម្រាក់ ... |
| មា ... | ទេវបុត្ត ... | ពាជី ... |
| មីង ... | ទេវធីតា ... | ពាជិនី ... |

| | | |
|---|---|---|
| តា... | នាងមេខលា... | តារី... |
| យាយ... | កិន្នរ... | ពានរ... |
| កុមារ... | កិន្នក... | ពានរី... |
| កុមាក... | កិន្នរី... | ទាយក... |
| កុមារី... | បក្ខ, បក្សា... | ទាយិកា... |
| ភិក្ខុ... | បក្សី... | ឧបាសក... |
| ភិក្ខុនី... | ព្រាហ្មណ៍... | ឧបាសិកា... |
| សាមណេរ... | ព្រាហ្មណី... | សិក្ខមានា... |
| សាមណេក... | តោក... | ទាសី... |
| សាមណេរី... | តោរី... | ទាសា... |

២– ប្ដូរដាក់វចនៈ៖ ត្រង់ពាក្យនាមនាមនិមួយៗ ។ ដោយមានដូចមនុស្សទាំងឡាយ (ពហុវចនៈ ប្ដូពហុ.) របស់, (ឯកវចនៈ ប្ដូឯក.)

| | |
|---|---|
| មនុស្សទាំងឡាយ... | សិស្សានុសិស្ស... |
| ឈើ... | កស្ត្រប្រជា... |

ក្មេង . . . ជនានុជន . . .

ផ្លែទាំងឡាយ . . . ឋានានុក្រម . . .

រាជាទាំងឡាយ . . . របស់ទាំងឡាយ . . .

សេះប្រាំ . . . ពស្ត្រា . . .

ដំរី . . . ផ្ទះទាំងឡាយ . . .

រទេះទាំងឡាយ . . . ព្រាហ្មណ៍ . . .

ឫស្សី . . . ភោជនាហារ . . .

កុមារ . . . ទោសានុទោស . . .

## ៣ - បកតិគុណនាម

| | | | |
|---|---|---|---|
| ល្អ | ប្រសប់ | ខ្ពស់ | ការ |
| មាំ | ស្រួយ | ទាប | ខាប់ |
| ជាប់ | ធុយ | ស្ងើត | ក្រអូប |
| ស្គម | រឹង | តំរក់ | ស្អុយ |
| ពូកែ | ទន់ | ក្ដី | ស្រួច |

| | | | |
|---|---|---|---|
| ធាត់ | ធំ | ស្រគាប់ | ទាល |
| ស | តូច | ខ្វី | ត្រង់ |
| ខ្មៅ | ស្តើង | វែង | វៀច |

៤- ចូរភ្ជាប់គុណនាមដូចមានខាងលើ ទឹងនាមនាមមួយ ៗ តាមសមគួរ ៗ ឧបមាដូច: ទន្លេវែង-ក្មេងគំរក់-ចុងកាំបិត... ៗ

| | | |
|---|---|---|
| ទន្លេ... | ភ្នំ... | បន្ទាត់... |
| ក្មេង... | បេស... | ផ្លូវ... |
| របង... | ស្លឹក... | មួក... |
| ឈើ... | មេឃ... | ឆត្រ... |
| ឆ្កែ... | កន្ទេង... | ទឹក... |
| មេទាហាន... | ពង... | ក្ដារ... |
| ក្រដាស... | មនុស្ស... | ដែក... |
| ធ្យូង... | ភ្លើង... | ដាងទង... |
| ដាង... | តញ្ញាក... | កែវ... |

## ៦៤– ថ្នាក់ មធ្យមដ្ឋាន និង ឧត្តមដ្ឋាន

| | | |
|---|---|---|
| ជស ... | បន្ទុលដៃ ... | ព្រះអាទិត្យ ... |
| ឥដ្ឋ ... | វត្ថុ ... | ចាន ... |
| ថ្ម ... | ផ្កា ... | ក្រមួន ... |
| ឈូក ... | កន្ទេល ... | ដំបៅ ... |

### ៥– អតិវិសេសគុណនាម

| | | | |
|---|---|---|---|
| ខ្មៅណាស់ | លឿនក្រៃ | ស្រួយពេក | តឹងម៉ឹង |
| ម៉ដ្ឋសុង | ខ្ពស់ត្រដែត | ធំធេង | ណែនក្តន់ |
| ភ្លឺរលោង | ខ្ចីក្រឡុញ | សក្បុស | កបធេង |
| ថ្លាយង់ | ឆើតឆាយ | ខៀវស្រងាត់ | ស្ដើងហៀរ |
| រហ័សប្រិល | ឆ្ងាយសន្ទឹម | ផុយរកម | មូលក្រឡង់ |

៦– ឱ្យនាមនាមទាំងនេះ ចូរដាក់លក្ខណៈនាមគួរសម នឹងអតិវិសេសគុណនាមខាងលើនោះឯង ។ ឧទាហរណ៍ ៖ សក់ ខ្មៅរលើង ... ។

សកមានពណ៌ ... ពលបាកយណ៍ផាកល ...

| | |
|---|---|
| ក្មេងនេះមានស្អាប់... | បានជាវិត្ត .. |
| ខ្ញុំមានគុ... | មើលទៅឃើញភូមិ... |
| ទឹកនេះ... | ភ្នំនោះមានពណ៌... |
| មនុស្សនេះ... | អម្បោះជាសរសៃ... |
| ព្រាយហោះ... | គេចងចំណង... |
| ថ្ងៃឡើង... | កែបនេះប្រកត... |
| ម្រាមដៃក្មេង... | ភូមិនេះសង់លើដី... |
| ពងរបស់កុមារនេះ... | ជញ្ជាំងផ្ទះនេះធ្វើនឹងក្ដារ... |
| ព្រៃនោះ... | ព្រះអាទិត្យមានរង់... |

## ៧ – វិសេសគុណនាម

| | | | |
|---|---|---|---|
| បេះជាង | ប្រសប់ជាង | ជាប់ជាង | ខ្មៅលើស |
| យឺតជាង | រហ័សជាង | ផុយជាង | សប្លែក |
| ល្អប្លែក | ខ្ពស់លើស | រឹងជាង | ល្អិតជាង |
| ថ្លាជាង | ធាត់ប្លែក | ទន់ជាង | ទាបជាង |

# ៦៦ – ថ្នាក់មធ្យមថ្នាក់ និង ឧត្តមថ្នាក់

៨ – ចូរដាក់លក្ខណៈតាមសមគួរ នឹងពាក្យនិមួយៗដោយ វិសេសគុណនាមខាងលើ ។ ឧទាហរណ៍ៈ ក្មេងនេះប្រសប់ជាង, កូនសិស្សនោះឆ្លាតជាង ... ។

ក្មេងទាំងឡាយ ក្មេងនេះ... ។ ឈើជាប់នោះផ្ចឹកជាឈើ ... ។ យានទាំងឡាយ រទេះគោ ... ។ ត្បូងពេជ្ររត្ន... ត្បូងទាំងអស់ ។ ភ្នំនៅស្រុកខ្មែរ - ភ្នំបូកគោ ... ។ គ្មានរបស់អ្វី... ជាងថ្ម ។ ទឹកម៉ាស៊ីន... ទឹកស្រះ ។ ដែកជាលោហធាតុ ... ធាតុឯទៀត ។ ស្បែកមនុស្សទាំងពួង ស្បែកបាំង... ។ គ្មានអ្វី ... លើស ម្រ័ក្សណ៍ខ្មែរ ។ ធម្មជាតិល្អិត គ្មានអ្វី ... អាកាស ។ វត្ថុទន់ នោះសំឡីជាសរសៃ ... ។

៩ – នូវកិរិយាទាំងឡាយ ចូរបំបែកជាកិតនាម ឬ នាមក្រិត ។ ឧបមាដូចពាក្យៈគិត ជាគំនិត, ខ្ទប់ ជាបន្ទប់ ... ។

គិត ... កាត់ ... សិត ... គូស ...

បង ... កោស ... សូន ... កាន់ ...

ឈាន ... ដឹង ... ដួញ ... បិត ...

ដោរ ... ទើរ ... ទិញ ... គេណ្ឌ ...

ដើរ ... ខួញ ... បត ... សៀត ...

ដេក ... បួស ... ប៉ះ ... កោរ ...

ដាំ ... បួង ... កាត់ ... គាល់ ...

ទំ ... ពូន ... រៀប ... សួរ ...

១០ — ចូររកនាមក្រិតចេញពីគុណនាមមួយ ៗ នេះ ៗ

ឧបមាដូច: ធ្ងន់ ជាទម្ងន់ ... ៗ

ធ្ងន់ ... ខ្វាក់ ... ចាំ ... ធំ ...

ទាប ... ខ្ទិន ... ស្អុយ ... ក្រាស់ ...

ខ្ពស់ ... ឈឺ ... ស្អាប ... ខ្ជិល ...

ស្រាល ... ចេះ ... ផ្អែម ... ឆ្ងាញ់ ...

រឹង ... ថ្លៃ ... ខ្លី ... ខ្សត់ ...

ល្ងប ... ស្ដើង ... ចាស់ ... ទាស់ ...

ណែក ... កាប ... ល្អ ... គួប ...

១១– ចូររកកិរិយាក្រិតចេញពីពាក្យមួយៗខាងក្រោមនេះៗ

ដូចពាក្យ : ត្រង់ ជា ដំរង់ ឬ តម្រង់ ... ៗ

ត្រង់ ... ដំនៀល ... ទំនាយ ... ទ្រនាប់ ...

ត្រូវ ... ចំណេញ... បំណាស់... ទំលាប់...

ដំណោះ... ចំណោទ... បំណុល... ស្អាត...

ថ្មើរ... ចំណាយ... អំនួត... ផ្នត់...

ទំនើប... ច្រើន... ទ្រទំ... ក្នៃន...

១២– ចូរភ្ជាប់បុព្វបទ " ក-ប-ប្រ-បង់-បញ-បណ-បន-បំ-ទ-ញ" និងពាក្យកិរិយានីមួយៗ តាមដោយសមគួរ ៗ

ដូច: កាយ ជា កកាយ, ការ ជា បង្ការ ៗ

កាយ ...: ជូន ... រួម ... ផុល ...

ការ ... ដោរ ... ថែម ... មើល ...

ខាត ... ល្បោះ ... ករ ... ខាំ ...

គរ ... ឈឺ ... ខាន ... ទំ...

គាប់... ដេញ... ឈាក់... ទាញ...

| | | | |
|---|---|---|---|
| បូល... | ដើរ... | ក្អួត... | រួញ... |
| ចេញ... | ដំ... | ខែរ... | ចាស់... |
| ឆុក... | រៀន... | បិទ... | ញឹម... |

១៣– ចូររកបុព្វបទដែលមានន័យថា: "ធ្វើឲ្យ" មកភ្ជាប់នឹងពាក្យនិមួយ ៗ នេះឧបមាដូចពាក្យ: "ខំ ជា បន្ខំ" ៗ

| | | | |
|---|---|---|---|
| ខំ... | រត់... | រៀប... | ខាំ... |
| កាប់... | ផល់... | បែក... | ខូច... |
| ស្លាប់... | ដឹង...... | ហាត់... | រួម... |
| កើត... | ខាន... | រលំ... | រឹត... |
| រៀន... | ឡើង... | យល់... | ផ្សំ... |
| ឈឺ... | ចុះ... | ចាស់... | ដុះ... |
| ដេក... | ភ្លឺ... | សិក្ខ... | ផ្តាច់... |
| ឈរ... | ទុំ... | ចាល់... | ប្តឹង... |

១៤– ចូររកគុណនាមដោយគួរតាមគាត មកបំពេញបទនៃពាក្យទាំងនេះ ៗ ឧបមាដូចពាក្យថា: "ពស់មានពិសជាសត្វកាច" ៗ

# ៣០ – ហ្វាក់ មជ្ឈិមដ្ឋាន នឹង ឧត្តមដ្ឋាន



ពស់មានពិសជាសត្វ... ។ មនុស្ស... គឺមនុស្សដែល មានរូបអវយវៈ ។ ខ្លាជាម្រឹគ... ។ គគីរជាឈើ... ហើយ... ណាស់ ។ ក្ដុំខ្លាលជាបពិត.... ។ ថ្មជាធាតុមួយ.... ។ មនុស្សឈើមានកាយ... ។ ផ្លែឈើទុំញោសមានក្លិន ... ។ អ្នកទុគ៌តជាមនុស្ស... ។ ព្រះចន្ទពេញបូណ៌មីមានរង្វង់... ។ ទឹកសមុទ្រមានរសជាតិ... ។ ភ្លើងជាធាតុ... ។ ដែកជា លោហធាតុ... ។ មេឃ... គឺមេឃដែលគ្មានពពក ។ លោ-ហធាតុ... គឺសំណ... ។ ខ្យល់ពីងដើងជាខ្យល់... ។ ពេជ្រ ជាត្បូង... ហើយ... បំផុត ។ ស្នោជារុក្ខជាតិមួយ... បំផុត ។ មនុស្សធ្វើការបានអាយជាមនុស្ស... ។ ព្រះអាទិត្យមានរស្មី... ។

១៥ – ចូររកកិរិយាមកភ្ជាប់នឹងប្រធាន :

ឧទាហរណ៍: ព្រះអាទិត្យ បំភ្លឺ លោក... ។

ព្រះអាទិត្យ... លោក ។ ជាងដែក... លោហធាតុ

ទឹងស្ងប់ ។ ព្រះចន្ទ... យប់ ។ ជាងបាយអ...

ឥដ្ឋធ្វើកំពែងវាំង ។ ព្រះធរណី... មនុស្សនិងសត្វ,

គ្រឹះក្រាន នៅក្នុងសំណុំព្រះពាម ។ គ្រូ... សិស្ស ។

ពស់... វ្រុំករវែក ។ ច្បាប់... ឲ្យយើង

ប្រតិបត្តិតាម ។ អណ្តើក...

ក្នុងទឹកនិងលើគោក ។



យើង... ប្រណិប័តន៍

ឪពុកម្តាយ ។ អ្នកទេសាចរ

ក្រិត... សំណាញ់ ។ ជាង

ង... មាសធ្វើប្រអប់ ។

ព្រានព្រៃ... សត្វទីងស្វា ។

## ៧២ — ថ្នាក់ មជ្ឈិមដ្ឋាន នឹង ឧត្តមដ្ឋាន



១៦ – ចូររកប្រធានតាមសភាពភ្ជាប់នឹងកិរិយានីមួយៗនេះ ៖

ឧទាហរណ៍ ៖ ចោរ លួច ទ្រព្យគេ ... ។

... លួចទ្រព្យគេ ។ ... កៀរត្រីនឹងព្រួល ។

... រៀនអក្សររៀនលេខ ។ ... បរដំរីនឹងកង្វេរ ។

... លេបកង្កែប ។ ... ជាផលជាតិ ។ ... សិក្សាធម៌ ។

... រស់នៅក្នុងទឹក ។ ... ដេញទន្សាយ ។ ... ចំឡងពាក្យដែលគ្រូបង្គាប់ ។ ... ឈប់សំរាកក្នុងសាលាទាន ។

... ពន្យល់ពាក្យនៅក្ដារខៀន ។ ... ធ្វើទានចំពោះសង្ឃ ។

... ដំដែកនឹងញញួរធំ ។ ... តយុទ្ធនឹងសត្រូវ ។ ... អុំទូកនឹងច្រវា ។

១៧– ចូររកពាក្យផ្ទុយទឹងពាក្យទាំងនេះ :

ឧទាហរណ៍: មនុស្សផ្គត់ផ្គង់: មនុស្សខ្ជះខ្ជាយ ...ៗ
មនុស្សផ្គត់ផ្គង់...ៗ ផ្លូវត្រង់ហើយវែង...ៗ ក្មេងឧស្សាហ៍...ៗ
សេះធាត់...ៗ កូនសិស្សខ្លាចខ្លួន... ៗ ឈើស្ងួត... ៗ
ជាងប្រសប់...ៗ ដៃករឹង... សំណ...ៗ មនុស្សអ្នក
មាន...ៗ អាចម៍ស្អុយ... ផ្កាចម្បា...ៗ មនុស្ស
ពាល...ៗ មាសលឿងទុំ... ប្រាក់...ៗ ផ្លែ
កាប...ៗ យប់ងងឹត... ថ្ងៃ...ៗ ផ្លែឈើទុំ...ៗ
ក្របីចាញ់ក្ដៅ... គោចាញ់...ៗ ស្បែកគគ្រាត...ៗ
សេះលឿន... គោ...ៗ កាំបិតមុត...ៗ ខ្លាធំ
ហើយសាហាវ... ឆ្មា... ហើយ...ៗ

១៨ – ចូររកពាក្យមកបំពេញកន្លែងចន្លោះ

ជនណាប្រតិបត្តិតាមច្បាប់នឹងបានសុខ, ជនណា... ច្បាប់
នឹងមានទោស ៗ ក្នុងសម័យដែលស្រុកសុខ, ការទាំងពួងបានចំ
រើន ៗ ក្នុងសម័យដែលស្រុកមាន..., ការទាំងពួងនឹងអន្តរាយ ៗ

មនុស្សណាដែលគិតតែសុខ, អ្នកនោះនឹងបាន... ។ នរណាយកទុក្ខមកជាទីតាំង, អ្នកនោះនឹងបាន... ។ ជនណាឃើញខ្លួនឯងថាជាមនុស្សក្រ, ជននោះនឹងជាអ្នក... ។ ជនណាឃើញខ្លួនឯងថាជាអ្នកប្រាជ្ញ, ជននោះជាបុគ្គល ... ។ នរណាតាំងខ្លួនជាខ្លៅ, នរណានោះជាអ្នក ... ។

១៩ — ចូររើសរកពាក្យដែលមានន័យប្រហែលគ្នា (វេវចនៈ នឹងពាក្យដូចមានតទៅ ៖

ឧបមាដូច: បរ គឺក្រាប់ - ទៅ - យាន - ទិមន្ត ...

| | | | |
|---|---|---|---|
| បរ... | យំ... | សំដៅ ... | បញ្ជូន ... |
| ដេក ... | ទិញ... | បិទ ... | ប្ដឹង... |
| ស៊ី... | ឲ្យ... | ដក... | ប្រដៅ... |
| មើល... | លេង... | លុប... | កាត់... |
| គិត... | ឈឺ... | បំពេញ... | បំភ្លឺ... |

# ៣០-សមាសនាម

នាមនាមមានច្រើនយ៉ាង ។ នាមដែលកើតឡើងឯង ៗ ហៅជាបកតិនាមដូចពាក្យៈ ផ្ទះ-សេះ-ដី... ។ នាមដែលបែកចេញពីកិរិយាឬពីគុណនាមហៅជានាមក្រិត ឬកិតនាម ដូចពាក្យៈ ដំណើរ-ជម្ងន់ ( មកពីដើរ - ពីធ្ងន់ ) ។

នាមដែលភ្ជាប់គួបគ្នាពីរពាក្យ ឬច្រើនពាក្យជានាមមួយហៅជាសមាសនាម ។ សមាសនាមជានាមគួបគ្នាដោយនាមនឹងនាមក៏មាន, ដោយនាមនឹងគុណនាមក៏មាន, ដោយនាមនឹងកិរិយាក៏មាន, ដោយកិរិយានឹងកិរិយាក៏មាន; សមាសនាមមានពីរយ៉ាងគឺៈ នាម-សមាសបាលី ១, នាមសមាសខ្មែរ ១ ។ នូវនាមសមាសបាលី បើកាលណាពាក្យដែលយកមកភ្ជាប់ ជាពាក្យកើតឡើងគំពីស្រៈពេញត្រូវផ្លាស់ស្រៈនោះជាស្រៈនិស្ស័យ ឧបមាដូចពាក្យៈ "គជ-ឥន្ទ្រ ជាគជេន្ទ្រ" "ជន-អធិបតី ជាជនាធិបតី" ។ សមាស-នាមទាំងឡាយគឺៈ ជង្គ្រនាង-ពស់វែក-ក្រដាសប៉ុយ-ដើងម៉ា-

# ៣៦ — ប្អាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

ច្រូតស្រូវ - គោសៀម - ថ្នាំកុឡា - ជណ្ដើរ - ជនានុជន - សិក្សាធិការ - លោកុត្តរ - សាសនោបាយ - ទេវិន្ទ ... ។

## វិធីហាត់

ចូរសរសេរតម្រូវសមាសនាមដូចមានខាងក្រោម ៖

សិស្ស + អនុសិស្ស = សិស្សានុសិស្ស ។ លោក + ឧត្តរ = ... ។ ជន + អនុជន = ... ។ លោក + ឥស្សរៈ = ... ។ គុណ + អានិសង្ស = ... ។ ពាន + ឥន្ទ្រ = ... ។ ផល + អាហារ = ... ។ សាសនៈ + ឧបាយ = ... ។ សព្វ + អធិដ្ឋាន = ... ។ ពុទ្ធ + អនុញ្ញាត = ... ។ គុណ + ឧបត្ថម្ភ = ... ។ ជន + អធិបតី = ... ។ ឧបជ្ឈាយ៍ + អាចារ្យ = ... ។ នរ + ឧត្តម = ... ។ ជន + អនុគ្រោះ = ... ។ គោបា ... ផ្ទះខ្ទរ ... ដើងម៉ា ... ណោរដែ... រខះគោ ... ។

ក្នុងភាសាខ្មែរគេប្រើកិរិយាស័ព្ទនិងគុណសព្ទជានាមជាច្រើនៗ ឧបមាដូចពាក្យថា៖ អ្នករែក - អ្នកទូល - អ្នកដើរ - អ្នកទៅ - អ្នកមក ... សឹងជាកិរិយាប្រើជានាម, អ្នកធំ - អ្នកតូច - អ្នកខ្ជិល - អ្នកប្រសប់-

អ្នកប្រាជ្ញ-អ្នកខ្លៅ... សឹងជាគុណនាមប្រើជានាម, នាមទាំងឡាយនេះហៅថាការកនាម ។

ចូរចុះសំគាល់ជាពាក្យៈ បកតិ, កិត, សមាស, ការកៈ នៅមុខនាមនិមួយៗ :

ឈើគូស (សមាស) ដំណែង... គោខ្មែរ... កាំភ្លើងដៃ...

ផ្លូវ... (បកតិ) បារី... អ្នកស្រែ... សិក្សាធិការ...

ដំណើរ... ប្រវែង... ម្តាយមីង...

គុណូបត្ថម្ភ... ដែក... អ្នកប្រាជ្ញ...

ឪពុកធំ... គជេន្ទ្រ... អ្នកបាំ...

ដំហាន... ម្តាយធំ... ឥន្ទ្រាធិរាជ...



ស្រូវស្រែ... ទឹកឃ្មុំ... រថភ្លើង... មហោសថ...

អ្នកខ្វិល... ផ្ទះផ្សារ... បន្ទាត់... ចតុរង្គ...

មនុស្ស... ទំនិញ... ដៃខ្មៅ... នាគរាជ...

សត្វ... ចានគ្រប... កាំបិតកោរ... ពានរ...

## ៣៨ – ហ្វាក់ មជ្ឈិមដ្ឋាន និង ឧត្តមដ្ឋាន

តិត្ថិក... សេះទិច... ឫស្សីស្រុក... យក្សិណី... ។

ពាក្យប្លែងរូបព្រោះផ្លាស់អក្សរសិងជាពាក្យកើតពីព្យញ្ជនៈ វ ។ ឧបមាដូចពាក្យៈ ពិលា = វិលា, ពិសាខ = វិសាខ ។

ចូរផ្លាស់តួ វ ជាតួ ព នូវពាក្យដូចមានតទៅ៖

វេលា... វេយ្យាករណ៍... វន... ទេវី... វាក្យ... វ្យាធិ... ហេមវន្ត... ទេវតា... វត្តា... វ្យាបាល... វុត្តិ... វេស្សា... វរៈ = ព្រះ... វារ... វៀរ... វ្ឫក្ស... វ្យញ្ជនៈ... វាយុ... ប្រថវី... វ្ឫហស្បតិ... ។

សេចក្តីបំណាំ – ពាក្យដែលផ្លាស់ វ ជា ព ច្រើនតែពាក្យបាលី និងពាក្យសំស្ក្រឹត ដែលប្រើក្នុងភាសាខ្មែរ ។

## ៣១ – ពាក្យកើតពីអក្សរ បដ្ឋថស្ឋស្តស្ន

ពាក្យជាច្រើនកើតពីអក្សរ បដ្ឋថស្ឋស្តស្ន ។ អក្សរ បដ្ឋ សម្រាប់តែពាក្យដែលជាបាលី ។ អក្សរ ស្ឋស្តស្ន សម្រាប់

តែពាក្យជាសំស្រ្កឹត ។ អក្សរ ថ ប្រើជាពាក្យក្លាយបាលីឬសំស្រ្កឹត ឬជាពាក្យខ្មែរសុទ្ធ ដូចពាក្យៈបឋម-ឋាន... ជាបាលី ។ ប្រថម-ស្ថាន...ជាសំស្រ្កឹត ។ បថម-ថាន... ក្លាយ ។ ថន ...បាលី ។ ស្តន ... សំស្រ្កឹត ។ ជេដ្ឋ ... បាលី ។ ជេស្ឋ ... សំស្រ្កឹត ។

## វិធីហាត់

ចូរផ្លាស់តួអក្សរ ឋដ្ឋជា ថ-ស្ថ-ស្ត-ស្ឋ តាមដោយភាពរបស់ពាក្យ ។ ឧបមាដូចពាក្យៈ បឋវី ផ្លាស់ជាប្រថវី ។

បឋវី... ថន... ថលបថ... ថូប...

ហត្ថ... ឋាវរ... ថលយាន... សារត្ថី...

ទុដ្ឋ... អធិដ្ឋាន... ឋានានុក្រម... ថនិកសត្វ...

ជេដ្ឋ... មតិដ្ឋាន... ឋិត... ថិ (ភេទផ្ទុយនឹងប្រុស)

ឋិតថេរ... វត្ថុ... រដ្ឋ... ឋានិយ..

ឋាន... ជយដ្ឋាន... ថម្ភ... គោឃាតដ្ឋាន...

## ៣២ – ព្យញ្ជនៈផ្លាស់រូប តែសព្ទគង់នៅដដែល

តួអក្សរខ្លះទៀតផ្លាស់រូប តែស័ព្ទរបស់ពាក្យនៅដដែល ដូចពាក្យៈ អក្ខរៈ ផ្លាស់ជាអក្សរ, ខេត្ត ផ្លាស់ ជា ក្សេត្រ, ខ័យ ជាក្ស័យ, ចក្ក ជាចក្រ, បុត្ត ជាបុត្រ, បញ្ញា ជាប្រាជ្ញា, កទ្ទបទ ជាកទ្របទ, បុញ្ញ ជាបុណ្យ, កិច្ច ជាក្រិត្យ, បច្ឆិម ជាបស្ចិម, អច្ឆរិយ ជាអស្ចារ្យ, វិជ្ជា ជាវិទ្យា, មជ្ឈិម ជាមធ្យម, ឈាន ជាធ្យាន, ពេជ្ជ ជាពេទ្យ ... ។

ព្យញ្ជនៈផ្លាស់តួដូចមានខាងលើ គឺ: ១- ក្ខ ផ្លាស់ជាក្ស, ត្ត - ទ្ទ - ក្ក ផ្លាស់ ជា ត្រ - ទ្រ - ក្រ, ច្ច ជា ត្យ, ជ្ជ ជា ទ្យ, ច្ឆ ជា ស្ច, ញ្ញជា ណ្យ - ន្យ, ញ ជា ជ្ញ, ឈ ជា ធ្យ ។

### វិធីហាត់

ចូរផ្លាស់តួព្យញ្ជនៈនៃពាក្យ បើតួនោះគួរគប្បីផ្លាស់ តាមអធ្យាស្រ័យ ។ ឧ. សមុទ្រ - ពុទ្ធចក្រ... ។

| | | | |
|---|---|---|---|
| សមុទ្ទ... | វីណាស្រែព... | អាទិច្ច... | បញ្ញា... |
| ពុទ្ធបក្ក... | មរក្ខន ... | អមច្ច... | បុញ្ញ... |
| ខត្ត, ខត្តិយ... | ទក្ខិណ ... | បច្ឆិម... | សុញ្ញ... |
| ខេត្ត... | ខេម... | បច្ចាមិត្ត... | កញ្ញា... |
| បុត្ត.. | គហាវាស... | អច្ឆរិយ... | អរញ្ញ... |
| អាយុខ័យ... | បរេច្ចក... | វិជ្ជា... | ទុក្ខិត... |
| អក្ខរៈ... | បច្ច័យ... | ពេជ្ជ, វេជ្ជ... | មោក្ខធម៌... |
| ខណៈ... | បច្ចូសកាល... | វិជ្ជាធរ... | ចិត្ត ... |
| កទ្ធបទ ... | កិច្ច...... | មជ្ឈ ... | មិត្ត ... |
| ខន្តី... | ពាក្យសច្ច ... | មាណវ... | មជ្ឈិម ... |

## ៣៣- អាខ្វាក់អាខ្វិននាំគ្នារត់



មានមនុស្សពិការពីរនាក់ ម្នាក់ខ្វាក់ ម្នាក់ខ្វិន នៅជាខ្ញុំគេវាំង ពីរនាក់ ប៉ុន្តែម្ចាស់ដោយខ្លួនពីគ្នា ៗ គេប្រើឲ្យធ្វើការផតអាណិតមេត្តាសោះម្ល៉េះ ហើយបុរសទាំងពីរគិតថា: នឹងរត់គេចលែងបំរើគេ ៗ លុះដល់យប់ក៏នាំគ្នាចុះទៅកំពង់ លួចទូកគេដះចេញទៅ វាអង្គុយឈមមុខទល់គ្នាចំប្រឹងអុំ ៗ ខណៈនោះយប់ងងឹតមើលអ្វីមិនឃើញ វាគិតស្មានថាទូកលឿនទៅមុខហើយ តែទូកនោះនៅ

វិលទៅមកនៅត្រង់កំពង់នោះដដែល ៗ លុះភ្លឺឡើងម្ចាស់ចុះមក ឃើញក៏ហៅឲ្យឡើងវិលទៅផ្ទះវិញ ៗ

នៅយូរបានបន្តិចមក អាខ្វាក់អាខ្វិនបបួលគ្នារត់ម្តងទៀត ហើយពិគ្រោះជាមុនថា: "យើងរត់លើកនេះ កុំឲ្យម្ចាស់យើងតាមទាន់ យើងទៅដើរគោកវិញ" អាខ្វាក់ឆ្លើយថា "ទៅដូចម្តេចបាន បើសុទ្ធតែខ្វាក់ខ្វិនយ៉ាងនេះ" អាខ្វិនឆ្លើយឡើងថា "ឯងកុំព្រួយ ឯងឲ្យអញជិះលើឯង ហើយអញបង្ហាញផ្លូវឯង" លុះដល់យប់ស្ងាត់ អាខ្វាក់លើកអាខ្វិនដើរចេញទៅដល់ស្រុកមួយ អាខ្វិនប្រទះឃើញខ្ទមគេចាំស្រែមួយ ហើយប្រាប់អាខ្វាក់ថា: "រឺយអាសំឡាញ់ មានខ្ទមមួយមានខ្សែព្រួរមួយបង្កាយ ចង្អេរមួយនឹងអណ្តើកមួយផង" អាខ្វាក់ឮហើយឆ្លើយថា: "អើរុយយកឲ្យអស់" ៗ អាខ្វិនថា: "យកធ្វើអ្វីធ្ងន់ឥតអំពើ" អាខ្វាក់ថា: "ធ្ងន់អ្វីឯង ធ្ងន់តែអញទេ, ចេះតែយកទៅ" អាខ្វាក់ក៏ប្រមូលយករបស់ទាំងអស់ ក្នុងទីនោះមានបាយមួយឆ្នាំងផង ដែលគេដាំទុកនៅជើងក្រានក៏យកទាំងអស់ស្រេច

ហើយអាខ្វិនឡើងជិះលើអាខ្វាក់ទៀត ឯអាខ្វាក់ជាមនុស្សខ្លាំងយករបស់ទាំងនោះទៅបាន ។

## ៣៤-សុភាទន្សាយបានសង្គ្រោះ

ត្រី - កំពីស - ក្តាម - ខ្យង ឲ្យរួចជីវិត

ទន្សាយទៅដល់មាត់បឹង ឃើញសត្វទាំងឡាយកំពុងតែបាចទឹក ក៏បេះស្លឹកឈើដែលមានផ្ការីករមាន ស្នាមក្រវេមក្រវាមមកក្លែងធ្វើជាសំបុត្រ ហើយស្រែកហៅសត្វទាំងឡាយនោះថា: "នែបងប្អូនទាំងអស់គ្នាស្តាប់ខ្ញុំ ! ដ្បិតព្រះឥន្ទ្រឲ្យខ្ញុំនាំសំបុត្រនេះមកប្រកាសប្រាប់អស់អ្នកពល់គ្នាថា : "ព្រះឥន្ទ្រលោកខឹងមក កាប់ដើមត្រុំផ្សំនឹងផើងអក កាប់ក្បាលចចកដកក្តុកដំរីសារ កាប់ក្បាលអាខ្លាឲ្យជ្រៅៗជាងគេ វះពោះអាគេ កាត់កអាថ្កាន់ ៗ សត្វទាំងអស់ឮដូច្នោះភ័យណាស់ ផ្អើលតោះឡោះបោលជាន់លើគ្នា ដំរី ក្របី រមាស រមាំង ខ្លា គោ ស្ទុះបោលទៅជាន់លើតស់



ថ្លាន់ដែលធ្វើជាទំនប់ ដាច់ខ្លួនជាពីរបីកំណាត់ ក្លាយទឹកលិច ស្លាប់អស់សត្វទាំងនោះទៅជាចំណីត្រីនិងអណ្តើកវិញ ។

តាំងអំពីថ្ងៃនោះមកសត្វទាំងអស់សឹងគោរពខ្លាចប្រាជ្ញាទន្សាយ ហើយហៅថាសុភាទន្សាយ ទាំងអស់គ្នាអំពីថ្ងៃនោះមក ។

# ៣៥ – វិជ្ជាសម្បត្តិ

ហៃសាធុជនទាំងអស់គ្នា  បំណេះវិជ្ជាទាំងសម្ពាយ
មានគុណវិសេសធំទូលាយ  គួរយើងរៀបស្ពាយកុំខ្លាចធ្ងន់ ។
មិនលំបាកទុកស្រណុកណាក់  ជាជាងមាសប្រាក់សព្វទ្រព្យធន
មិនខ្លាចចោរលួចឬចោរប្លន់  ទៅគ្រប់ជម្ពូទ់គ្រាន់ជាស្បៀង ។
ឥតកណ្ដៀរកេរកណ្ដុរកាត់  ចាយណាស់មិនបាត់មិនមានល្អៀង
ប្រើច្រើនកើតច្រើនចំរើនទៀង  ពីបច្ចុប្បន្នរៀងទៅបរលោក ។
មានសុវិជ្ជាគង់មានទ្រព្យ  អ្នកផងមិនស្អប់មិត្តមូលមក
មានមិត្តហើយបុណ្យតែងរត់រក  ស្លាប់ទៅបរលោកយោគស្ថានសួគ៌ ។

## ៣៦ – នាងកង្រីថ្វាយសេចក្តីស្ងាត់ កំបាំងដល់រទ្ធិសែន

ប្រពាតសួនរួចហើយ ទៅដល់មុខទ្វារឃ្លាំងតូបមួយនៅស្ងាត់ដាច់សន្ធឹងឆ្ងាយពីកន្លែងដទៃ នាងកង្រីឈប់ស្ងាំងកាំងកាន់កាំងស្មារតី ហើយភ័យណាស់ ទើបទូលស្វាមីថា: ឃ្លាំងនេះមានការសម្ងាត់ មាតាខ្ញុំម្ចាស់ហាមផ្ដាច់មិនឲ្យប្រាប់អ្នកណាឲ្យដឹងថាមានរបស់អ្វីៗសោះឡើយ ។

នាងវិតចូលទៅជិតស្វាមីហើយទូលថា: ក្នុងឃ្លាំងនេះ នៅលើតុមួយមានពានប្រាក់មួយក្រឡៃមាស ក្នុងពាននោះមានក្អែកស្រីពីរដណ្ដប់ទាក់ ហើយនៅជិតពាននោះមានដបមួយ ក្នុងដបនោះមានថ្នាំដាក់ក្អែកខ្វាក់ឲ្យជាវិញ ។ បើអ្នកណាខ្វាក់ក្អែកជ្រុះប្រែស្រីចេញ គ្រាន់តែដាក់គ្រាប់ក្អែកក្នុងរន្ធធំទៅវិញហើយលាបថ្នាំនេះទៅ នោះក្អែកនឹងជាឡើងហើយភ្លឺដូចដើមវិញហោង ។

# ៨៨–ហ្វាកម្មព្រហ្មជាតិ និង ឧត្តមជាតិ



រិទ្ធិសែនរំអត់សង្កត់ព្រះទ័យអំពីសេចក្តីទុក្ខសោក ហើយ ស្តេចនាំនាងកង្រីវិលទៅប្រាសាទវិញៈហោង ៗ

លុះដល់យប់ ពេលសោយក្រយាស្ងោយ រិទ្ធិសែនបំផឹកស្រានាងកង្រី ហើយទឹងពួកពលយក្សទាំងអស់ឲ្យស្រវឹងគ្រប់គ្នា លួងលោមឲ្យដេកលក់ទៅ ហើយលបយកកូនសោទ្វារឃ្លាំងពីនាងកង្រីបាន ។ ស្តេចយាងទៅយកភ្នែកនាងពីរដណ្តាប់ យកដបថ្នាំ ហើយនឹងដំបងផង ។ ទើបស្តេចយាងមកឧបថ្ម ណានាង

កង្រីដែលកំពុងដេកលក់មិនដឹងខ្លួនហោះនោះ    រួបទៀងគង់សេះ
រត់ទៅ ៗ

## ៣៧– សត្វទុងនឹងត្រី



មានសត្វទុងមួយ ជាសត្វកាន់សក្កាយទិដ្ឋិ ៗ ថ្ងៃមួយវាចេញស្វែងរកចាប់ត្រីជាអាហារ ៗ លុះហើរទៅបានឃើញត្រីក្អិតមួយ នៅខាងមាត់ខ្លួនទុងនោះក៏ចឹកត្រីក្អិតនោះបាន ទើបមកគិតថា អាត្មាអញនេះជាបក្សីរូបធំត្រូវតែបរិភោគត្រីធំ ៗ យ៉ាងត្រីរស់ ត្រីឆ្ដោ ត្រីប្រាជាដើម នោះទើបសមនឹងសក្ដិយសរូបអញនេះ អាត្រីក្អិតរូបតូចមួយនេះមិនសមគួរនឹងរូបអញឡើយ គិតហើយទុងក៏លែងចោលបង់ ហើយហើរទៅមុខទៀត បានឃើញត្រីបង្វាក្រៀងមួយ ទុងក៏ចឹកបានឡើងនឹងស៊ី ក៏គិតថា: ត្រីបង្វាក្រៀងនេះតូចពេកណាស់ ពុំគួរនឹងរូបអញជាធំ គិតហើយ

ក៏លែងត្រីនោះចោលបង់ ហើយខំហែលទឹកស្វែងទៅមុខទៀត ស្វែងទៅៗរកត្រីពុំបាន ពេលសោតក៏ទន់ទាបល្ងាចនឹងផុតពេល ស្វែង ចុងនោះឯង កើតក្ដីឃ្លានអាហារមហិមា ខំស្វែងរកអាហារ ពុំបានឡើយ ម្ល៉ោះហើយចុងកើតទុក្ខ មុខស្ងុបសៅកើតក្ដៅចិត្ត គិតស្ដាយអាហារដែលខ្លួនរកបានអំពីព្រឹក ៗ

## ៣៨ – ស្ត្រីពីរនាក់ដណ្ដើមកូនគ្នា

មានស្ត្រីពីរនាក់មានកូនដូចគ្នា ម្នាក់កូនទើបនឹងស្លាប់ទៅ ម្នាក់កូននៅរស់ហើយពកូនយកទៅផ្ងូតទឹក ៗ ឯស្ត្រីកូនស្លាប់នោះ ដើរមកដួបហើយស្រដីថា: "កូននាងដូចកូនអញណាស់ នាងអើយ អញសូមបើបកូននាងបន្តិច" ៗ នាងម្ដាយក៏ឲ្យកូនទៅ ស្ត្រីនោះ ទទួលយកមកបើបបំបៅហើយយកកូនគេដើរទៅលំនៅខ្លួន ៗ នាងម្ដាយស្រែកហៅថា: "នាងអើយ! នាងយកកូនអញទៅឯណា" ៗ ស្ត្រីនោះតបថា: "កូនអញទេតើ ម្ដេចក៏មេថាកូនមេ" ៗ ម្ល៉ោះហើយ ឈ្លោះប្រកែកគ្នាទៅវិញទៅមក រួចនាំគ្នាទៅប្ដឹងចៅក្រម ៗ



ចៅក្រមជំនុំពិភាក្សាកាត់សេចក្តីនេះពុំបាន ទើបនាំស្ត្រីទាំងពីរនោះឡើងទៅ ក្រាបទូលសម្តេចព្រះមហាក្សត្រាធិរាជដោយនូវដំណើរនោះ ៗ ព្រះអង្គទ្រង់ជ្រាបសព្វគ្រប់ ហើយត្រាស់ឲ្យយកកូននោះទៅដាក់នៅនាទីកណ្តាលឲ្យដណ្តើមគ្នា ត្រាស់ថា៖ បើនរណាដណ្តើមបាន ឲ្យអ្នកនោះយកកូននោះចុះ ៗ

កាលបើដូច្នោះគូរ ស្ត្រីទាំងពីរចូលដណ្តើមគ្នា, ឯស្ត្រីស្មាប់កូន ចាប់ខ្ញាំយូរពុំគិតបាក់បែកហែកដៃជើង ឥតករុណាប្រណី

ជាក្មួនឡើយ ។ ឯម្ដាយយល់ឃើញមេនោះវាចំពុះពារប្រវ៉ាកូនជាប់ពុំគិតបាក់បែកឡើយក៏លែងកូនឲ្យបានទៅវាទៅ ។ ទើបព្រះអង្គមានព្រះបន្ទូលត្រាស់ថា: ព្រះស្ត្រីលែងកូនឲ្យបានទៅគេនោះហេតុដ្បិតអាសូរករុណាកូន ព្រះស្ត្រីនោះឯងជាម្ដាយពិតម៉ែន ។ ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ទ្រង់កាត់សេចក្ដីឲ្យបានកូននេះទៅម្ដាយវិញ រីឯមេដណ្ដើមកូនគេនោះ ព្រះអង្គឲ្យផ្ដន្ទាធ្វើទោស ។

## ៣៩ - រឿងខ្លាឃ្មុំនឹងដើមពង្រ



ខ្លាឃ្មុំមួយ ទៅដេកនៅក្រោមដើមពង្រ ១ ដើម លុះដេកលក់បន្តិចទៅមែកពង្របាក់ធ្លាក់មកត្រូវក្បាល ខ្លាឃ្មុំក៏ភ្ញាក់ក្រោកឡើងម៊ឹម៊ាបានក្ដីឈឺក្បាលពន់ពេកណាស់ក៏

ដើរចេញពាកទីនោះ ហើយនឹកខឹងនឹងដើមពង្រក៏ចងអាឃាត ។ គ្រាកាលនោះ មានអ្នករទេះម្នាក់បររទេះមកត្រង់ទីនោះ ជួនជាភ្លៅរទេះបាក់ក៏ឈប់ ហើយកាន់ពូថៅដើរចូលព្រៃ ដើម្បីនឹងកាប់ឈើធ្វើភ្លៅរទេះ ។ លុះដើរៗទៅបានជួបនឹងខ្លាឃ្មុំកណ្ដាលព្រៃ ។ ខ្លាឃ្មុំក៏សួរថា: អ្នកបងឯងដើររកអ្វី ចៅនោះក៏ប្រាប់ថា: យើងដើររកកាប់ឈើធ្វើភ្លៅរទេះ ខ្លាឃ្មុំបានឱកាសទើបប្រាប់ទៅថា: ឈើសម្រាប់ធ្វើភ្លៅរទេះ គ្មានឈើអ្វីជាប់ស៊ិតដូចដើមពង្រទេ ចូរអ្នកឯង ទៅកាប់ដើមពង្រឯណោះចុះ ។ អ្នករទេះក៏ចូលទៅកាប់ដើមពង្រនោះ តាមខ្លាឃ្មុំប្រាប់ ។ ឯដើមពង្រនោះជាលំនៅនៃរុក្ខទេវតា ។ កាលបើឃើញមនុស្សកាប់លំនៅខ្លួនដូច្នោះ ក៏ចេញមកសួរថា អ្នកកាប់ដើមពង្រដើម្បីការអ្វី? ចៅនោះប្រាប់ថាយកទៅធ្វើភ្លៅរទេះ ដ្បិតខ្លាឃ្មុំបានប្រាប់ថា ឈើនេះជាប់ល្អណាស់ ។ រុក្ខទេវតាដឹងថាខ្លាឃ្មុំចងគំនុំនឹងដើមពង្រក៏ប្រាប់ថា បើបានខ្លាញ់ខ្លាឃ្មុំមកលាបនោះ ទើបស៊ិតជាប់ល្អបរទៅសប្បាយ បើដូច្នេះចូរអ្នកឯងទៅសម្លាប់ខ្លាឃ្មុំយកខ្លាញ់វាទុកលាបភ្លៅរទេះអ្នកទៅ ។

# ៤០ - ឆ្មាស្រុកនឹងចាបពូក



ឆ្មាស្រុកមួយ ចាបពូកមួយ នៅជាមួយគ្នា ។ ថ្ងៃមួយមានចាបព្រៃ ហើរមកទំនៅទីជិតចាបពូកនោះ ហើយពោលពាក្យតិះដៀល ចាបនៅក្នុងទ្រុង ចាបក្នុងទ្រុងក៏កើតទោសោះឡើង ទើបដេរប្រទេចទៅចាបព្រៃវិញ ។ ជម្លោះដេរគ្នាទៅវិញទៅមកក៏កើតឡើងតែនឹងប្រប៉ឹកគ្នាពុំបាន ព្រោះមួយនៅក្នុងទ្រុង មួយនៅក្រៅទ្រុង ។ ឯឆ្មាស្រុកបានឮចាបទាំងពីរឈ្លោះគ្នាដូច្នោះ ក៏ខឹងហើយគិតថា "អាសត្វចាបព្រៃ ហេតុអ្វីវាមកឈ្លោះប្រកែកនឹងចាបជាសំឡាញ់អញអេះ, បើដូច្នេះអញនឹងជួយចាបជាសំឡាញ់ចុះ" ។ គិតហើយឆ្មានោះចាប់ចាបព្រៃនោះបាន ហើយទំពាស៊ីជាចម្ងាញ់ ។ "ឱ ! អញមិនដឹងជាសាច់ចាបព្រៃមានរសជាតិឆ្ងាញ់ដល់ម្ល៉េះសោះ បើដូច្នេះ ចាប់ដើមតាំងពីថ្ងៃនេះទៅ អញនឹងស្វែងចាប់ចាបព្រៃ

អាស្រ័យ» ។ ឆ្មានោះគិតដូច្នោះហើយ ពីថ្ងៃនោះមកតាំងស្វែងលបចាប់ចាបព្រៃអាស្រ័យជានិរន្តរ៍ ។ ថ្ងៃមួយឆ្មានោះរកចាប់ចាបព្រៃពុំបាន ដោយញ៉ាមមាត់អត់ពុំបាន ក៏ហែកទ្រុងចូលទៅចាប់ចាបជាសំឡាញ់បរិភោគតាមក្តីប្រាថ្នាហោង ។

## ៤១- ត្នោនឹងថ្នក់ទំពក់នៅដៃ

មានអមាត្យមួយនាក់ តែងរក្សាដើមត្នោព្រះរាជទ្រព្យព្រះមហាក្សត្រាធិរាជ គាត់រាប់ផ្លែត្នោនោះរៀងរាល់ថ្ងៃ បើមានផ្លែណាទុំគាត់បេះទៅថ្វាយស្តេច ។ គាប់ជួនថ្ងៃមួយមានបុរសម្នាក់យកទំពក់ទៅបេះផ្លែត្នោអំពីព្រៃឯទៀតទេ តែបុរសនោះលីទំពក់ដក់ផ្លែត្នោដើរទៅទៀបខាងដើមត្នោ អមាត្យមើលទៅយល់បុរសនោះមានទំពក់នៅដៃ និងផ្លែត្នោនៅថ្នក់ ទើបគាត់ទៅរាប់ផ្លែត្នោរបស់គាត់មើល លុះពិនិត្យទៅឃើញទងខ្វះ ទើបគាត់គិតថា: នេះសមអាលីទំពក់បេះផ្លែត្នោនេះ ដក់ទៅអំបាញ់មិញនេះឯងជាចោរលួចបេះផ្លែត្នោស្តេចមិនខានឡើយ ។ ទើបអមាត្យក៏រត់ទៅតាម

## ៩៦ – ប្តាក់ មជ្ឈិមជ្ជន និង ឧត្តមជ្ជន



ចៅនោះ ឃើញផ្លែល្ពៅនៅចុងទំពក់នៅដៃ ហើយគេកោះយកចៅនោះទៅក្រាបទូលសម្តេចព្រះមហាក្សត្រាធិរាជ ដោយដំណើរសព្វគ្រប់ ៗ ព្រះអង្គមានព្រះបន្ទូលថាកុំអាលគាបវាឡើយ ឲ្យយកផ្លែល្ពៅចៅនេះទៅផ្សាប់នឹងទង បើវាត្រូវឲ្យទំលាក់អំពីទងនោះមកដីមើល វាជ្រុះទៅត្រង់ណា ឲ្យពិចារណាតាមដោយទូវហេតុនោះហោង ។

អមាត្យយកផ្លែល្ពៅទៅផ្គាប់នឹងទងនោះមិនត្រូវឡើយ ព្រះអង្គបង្គាប់ឲ្យទំលាក់មកដី ផ្លែល្ពៅជ្រុះទៅក្នុងថក់ភក់ រួចព្រះអង្គឲ្យគេកាយភក់យកផ្លែល្ពៅនោះមកវិញ ។ ព្រះអង្គឲ្យយកផ្លែល្ពៅជ្រុះពីថ្ងៃមុននោះទៅផ្គាប់នឹងទងដដែល មើលឃើញត្រូវមែន ទើបទ្រង់ព្រះរាជទានផ្លែល្ពៅដែលដក់ទៅហៅនោះវិញ បុរសនោះក៏ក្រាបលាយកទំពក់នឹងផ្លែល្ពៅទៅលំនៅអាត្មា ។

## ៤២- រឿងសត្វបក្សី

មានសត្វបក្សីមួយ អាស្រ័យនៅលើខ្លោងទ្វារព្រះរាជវាំងនៃព្រះបាទវិទេហក្សត្រ នៅក្នុងនគរមិថិលា បក្សីនោះបានឃើញស្តេចយាងចេញចូលតាមទ្វារនោះកាលណា ក៏ចុះមកដីធ្វើសរសើផ្គក់ៗ គឺគំនាប់គោរពព្រះបរមរាជាតែរាល់ៗ កាល ។ ឯព្រះបាទវិទេហក្សត្រ ស្តេចយល់អាការកិរិយាបក្សីនោះហើយ ក៏ត្រាស់សួរទៅមហោសថបណ្ឌិតពោធិសត្វ ក្រាបទូលតាមហេតុដែលបក្សីឱនបង្គំព្រះបរមរាជា ទើបស្តេចមានព្រះហឫទ័យ

ត្រកអរនឹងបក្សីយនោះឯង ហើយទ្រង់ប្រោសប្រាណព្រះរាជទានមាសមួយពៃក្ដាម បើកឲ្យនាយពិសេសទិញសាច់ឲ្យបក្សីយអាស្រ័យតាមកាលសម័យពីថ្ងៃនោះមក ឯបក្សីយក៏បាននៅសុខសប្បាយពុំបានខ្វល់ខ្វាយចេញទៅស្វែងរកអាហារឯណាឡើយ ។

## ៤៣—អទិន្នបុព្វកៈ

មានព្រាហ្មណ៍ម្នាក់ឈ្មោះអទិន្នបុព្វកៈ នៅក្នុងនគរសាវត្ថី ។ បានជាឈ្មោះដូច្នេះដោយហេតុថា ព្រាហ្មណ៍នោះជាមនុស្សកំណាញ់ កាញ់សម្បត្តិទុក មិនដែលបរិច្ចាគទ្រព្យ ចេញធ្វើបុណ្យឲ្យទានដល់សមណព្រាហ្មណ៍ និងស្មូមយាចកទាំងឡាយឡើយ ។ ព្រាហ្មណ៍នោះមានកូនប្រុសម្នាក់ឈ្មោះមដ្ឋកុណ្ឌលី បានជាមានឈ្មោះដូច្នេះព្រោះកូននោះបំរើនធំឡើងហើយ អទិន្នបុព្វក-ព្រាហ្មណ៍ជាបិតាប្រារព្ធនឹងធ្វើកុណ្ឌលជាគ្រឿងបំពាក់ឲ្យនោះនឹងទៅជួលជាងទងធ្វើក្រែងបង់ថ្លៃឈ្នួល ទើបព្រាហ្មណ៍យកមាសមកដំដោយខ្លួនឯងធ្វើកុណ្ឌល ។ លុះចំណោមក មដ្ឋកុណ្ឌលី

នោះមានជម្ងឺឈឺ គឺរោគលឿង ។ ទើបនាងព្រាហ្មណីនិយាយនឹងប្ដីថា: អ្នកអើយកូនយើងស្គម កើតលឿងឈឺរីងរៃយ៉ាងនេះ គួរអ្នកទៅរកគ្រូពេទ្យមកមើលមករក្សា, ឯព្រាហ្មណ៍ជាអ្នកខ្លាចបង់ខាតសម្បត្តិ ក៏ធ្វើព្រងើយកន្តើយមិនអើពើក្នុងការរកគ្រូមករក្សាកូនឡើយ ។ ឯរោគកូននោះរឹងរឹតតែឈឺធ្ងន់ឡើង ព្រាហ្មណ៍យល់អាការរោគកូនកាន់តែឈឺធ្ងន់ទើបគិតថា «កូនអញនឹងទុកឲ្យនៅក្នុងផ្ទះនេះយល់ជាពុំបាន ក្រែងពួកញាតិមិត្តទាំងឡាយគេចូលមកសួរជម្ងឺ គេនឹងឃើញទ្រព្យសម្បត្តិអញហើយគេនឹងមកកួនខ្ចីប្ដសុំអញ » ។ ព្រាហ្មណ៍នឹងប្រពន្ធនាំគ្នាសែងគ្រែកូនចេញមកដាក់នៅល្វែងតាកផ្ទះ ។ ឯចៅមដ្ឋកុណ្ឌលីកុមារនោះលុះរោគកំរើកខ្លាំងឡើងហើយ ក៏ដល់នូវកាលកិរិយាក្ស័យព្ឋជឺកាលនោះហោង ។

## ៤៤- ស្ទូចត្រី

គូកនពីរនាក់ គឹមនឹងសាន រៀននៅសាលាជាមួយគ្នា



ឆ្លៀតឱកាសថ្ងៃព្រហស្បតិ៍ ក៏ទៅស្ទូចត្រី នៅមាត់ស្ទឹងសែន ។ លុះព្រឹកឡើងវា នាំគ្នាចេញទៅពីព្រលឹម ដ៏មាន សម្លៀកបំពាក់ចាស់ៗ មួកធំដើម្បីបាំង បំហាយព្រះអាទិត្យផង ។ ចៅគឹមលីដងសន្ទូចមួយ ដ៏មានខ្សែផ្ទួ សន្ទូចកំសួលនឹងប្រអប់ស៊ីវិឡាគដាក់នុយ ។ ចៅសានកាន់ល្អី ស្បៀងអាហារ ។ ក្មេងទាំងពីរនាក់ទៅឈប់នៅកន្លែងមួយ នាមាត់ទឹកដ៏មានម្លប់ល្អ វាស្ទូចនៅទ៊ុះ ។ ជម្ស្រគ្មានត្រីមកស៊ីសោះ គឹមនឹងសានពុំហ៊ានកំរើកខ្លួនឡើយ ក្រែងត្រីផ្អើល ។ មួយស្របក់ មានត្រីប្រេនហាបហាលនាខ្នងទឹក ។ កំសួលសន្ទូចកញ្ជ្រោល ឡើងម្តងៗ គឺត្រីស៊ីសន្ទូចវាវាត់ដងសន្ទូចឡើងបានត្រី ។ មិនយូរ

ប៉ុន្មានវាបានត្រីពេញត្រកវាសប្បាយចិត្តក៏នាំគ្នាត្រឡប់ទៅផ្ទះវិញ ។ ម្ដាយវាទាំងពីរនាក់ក៏មានសេចក្ដីរីករាយ ហើយយកត្រីធ្វើម្ហូបស៊ីបាយ ។

## ៤៥- ផ្លែមង្ឃុត

សាននិងខុំកាន់ដៃគ្នាដើរលេង ។ ដើរបានបន្តិចទៅវា




ប្រទះផ្លែមង្ឃុតមួយនៅកណ្ដាលផ្លូវ ។ សាននិយាយថា: ផ្លែមង្ឃុតនេះត្រូវបានអញ ព្រោះអញបានឃើញមុន ។ ខុំថាត្រូវបានអញទេ ព្រោះអញរើសបាន ។ ក្មេងទាំងពីរនាក់ចេះតែជជែកហៀបតែប្រវាយប្រតប់គ្នា ។ មានក្មេងម្នាក់ទៀត ឈ្មោះសារី មកដល់ទីនោះ វាឈរនៅចន្លោះក្មេងទាំងពីរ ហើយសួររកដើមហេតុ រួចក៏យកកាំបិតបកពីហោប៉ៅអាវ វាពុះមង្ឃុតជាពីរ

ហើយនិយាយថាៈ សំបកមង្ឃុតមួយចំហៀងនេះ ត្រូវបានទៅសាខ ដែលបានឃើញមុន ឯសំបកមួយចំហៀងនេះទៀតត្រូវបានទៅខ្ញុំ ដែលបានរើស, រីខ្លួនអញ ដូចជាគេថា តែធ្វើការអ្វីត្រូវមានឈ្នួល, បើដូច្នេះ អញត្រូវបានសាច់ ជារួចហើយ សារីពមសាច់មង្ឃុតទៅ ។

## ៤៦ - ដេញចាប់ចោរ ៗ ចាប់វិញ



បុរសមួយនាក់ដេកលើសាលា ។ អាចោរម្នាក់លួចគាគោ ។

ដេញឈ្លូទៅ ៗ បុរសដេកលើសាលា ក៏ស្ទុះលោតចុះទៅ ចាប់បានអាចោរ ៗ លុះម្ចាស់គោតាមទៅទាន់ អាចោរស្រដីប្រាប់ទៅថា: ចៅនេះឯងលួចគោអ្នក ៗ ឯបុរសដេកលើសាលាឆ្លើយឡើងថា: ចៅឯងលួចគោគេអញចាប់ចៅឯងបាន ម្ដេចចៅមកថាអញវិញ ៗ ម្ចាស់គោយល់ថាប្រកែកគ្នាដូរឈ្មោះហើយទឹងចាប់តែម្នាក់ឯងខ្លាចក្រែងពុំមែនចោរនោះ ទើបចាប់មនុស្សទាំងពីរទៅប្ដឹងចៅក្រមឲ្យជំនុំជំរះ តាមពាក្យបណ្ដឹងទាំងសងខាង ៗ ចៅក្រមពិចារណាកាត់សេចក្ដីនោះពុំបានឡើយ ក៏នាំឡើងទៅក្រាបទូលក្សត្រាធិរាជដោយដំណើរនោះ ៗ ព្រះអង្គទ្រង់ព្រះចិន្ដាត្រាស់បង្គាប់ឲ្យយកមនុស្សទាំងពីរនាក់នេះទៅចងឲ្យមូសខាំ ហើយឲ្យអមាត្យទៅលបចាំស្ដាប់ពាក្យចៅទាំងពីរនោះ ៗ ចៅដែលដេកលើសាលាពោលរង្ហូរថា: បងតែឯង លួចគោគេទើបគេចងអញឲ្យមូសខាំ ៗ អាចោរថាអញលួចតែអញ ហេតុអ្វីក៏ទៅចាប់អញ

ព្រោះតែចាប់អញ ទើបគេបានអញមក  អមាត្យកត់ពាក្យចៅទាំងពីរនោះ ហើយនាំឡើងទៅថ្វាយក្សត្រាធិរាជ  ព្រះអង្គបង្គាប់ឲ្យពិន័យអាចោរមួយជាប្អូន គឺយកទ្រព្យដើមចេញ ហើយចែកក្រយាពិន័យជាភាគបី  ភាគមួយបានទៅម្ចាស់គោ  ភាគពីរបានទៅចៅដែលចាប់បានគូចោរនោះ ។

---

## សារទាន


| មាតិកា | ទំព័រ |
|---|---|
| វេយ្យាករណ៍ (អក្សរ - ស្រៈ) ... | ១ |
| ព្យញ្ជនៈ | ២ |
| អក្សរអឃោសៈ-ឃោសៈ-សិថិល ... | ៣ |
| គូអក្សរ | ៤ |
| គូព្យញ្ជនៈបន្ថែម - វណ្ណយុត្តិ .... | ៥ |
| វិធីប្រើវណ្ណយុត្តិ | ៦ |
| អក្សរព្យញ្ជនៈផ្លាស់ប្តូររូប ...., | ១២ |
| វិធីស្វាព្យាយន៍ចាំមាត់ | ១៣ |
| វណ្ណយុត្តិ-មេសូត្រ (ព្រហ្មគិត) .. | ១៤ |
| មុខងារនៃអក្សរ | ១៨ |
| ព្យាង្គរបស់ពាក្យ | ១៩ |
| ព្យាង្គតម្រួត | ២០ |
| សំឡេងអក្សរអឃោសៈ-ឃោសៈ .. | ២១ |
| នាមក្រិត - កិរិយាក្រិត | ២២ |
| នាម | ២៥ |
| លិង្គរបស់នាម | ២៧ |
| វិចនៈ | ២៨ |
| គុណនាម | ២៩ |
| កិរិយាសព្ទ ឬ កិរិយា ...... | ៣១ |
| វិធីហាត់ពាក្យមានបន្តក់នឹងឥតបន្តក់ | ៣៣ |
| សព្វនាម | ៣៤ |
| កិរិយាវិសេសន៍ | ៣៥ |
| វិធីប្រើអាយតនិបាត | ៣៦ |


## សារទាន


| មាតិកា | ទំព័រ |
|---|---|
| និបាតស័ព្ទ | ៤៦ |
| សំខ្យា ឬ សំខ្យាសព្ទ | ៥២ |
| បុព្វបទ | ៥៤ |
| អាគម - ឧបសគ្គៈ | ៥៥ |
| សម្ពន្ធ | ៥៨ |
| សមាសនាម | ៧៥ |
| ពាក្យកើតពីអក្សរ ឫ ដ្ឋ ឋ ស្ន ស្ដ ស្ថ | ៧៨ |
| ព្យញ្ជនៈផ្លាស់រូបតែសព្ទគង់នៅដដែល | ៨០ |
| អាខ្វាក់អាខ្វិននាំគ្នារត់ | ៨២ |
| សុភាទន្សាយ បានសះគ្រោះត្រី, ... | ៨៤ |
| វិជ្ជាសម្បត្តិ | ៨៦ |
| នាងកង្រី ... រថសេន | ៨៧ |
| សត្វទុងនឹងត្រី | ៨៩ |
| ស្ត្រីពីរនាក់ដណ្តើមកូនគ្នា | ៩០ |
| រឿងខ្លាឃ្មុំនឹងដើមពង្រ | ៩២ |
| ឆ្មាស្រុកនឹងចាបពូក | ៩៤ |
| ញោននឹងថ្នក់ទំពក់នៅដៃ | ៩៥ |
| រឿងសត្វបង្កួយ | ៩៧ |
| អទិន្នបុព្វកៈ | ៩៨ |
| ស្លូបត្រី | ១០០ |
| ផ្លែមង្គុត | ១០១ |
| ដេញចាប់ចោរ ៗ ចាប់វិញ ...., | ១០២ |

បោះនៅរោងពុម្ពខេមររដ្ឋ

ដំកល់ទុកតាមបញ្ញត្តិ

ឆ្នាំ ១៩៥៥

រោងពុម្ពខេមរដ្ឋ

អនាម័យ .......... ១០៛០០

មាត្រាម៉ែត្រ ........ ៥៛០០

គណិតវិធាន ........ ១៣៛០០

ធរណីមាណសាស្ត្រ .... ១៥៛០០

វេយ្យាករណ៍ភាសាខ្មែរ ... ១៥៛០០

វេយ្យាករណ៍ខ្មែរ ...... ១៧៛០០

ភូមិសាស្ត្រប្រទេសកម្ពុជា .. ៨៛០០

វិធីសិក្សាកុមារដ្ឋាន .... ១០៛០០

អប់រំសីលធម៌ ......... ៨៛០០

កម្រាផ្សង៉ព្រេងកំសនា .... ៨៛០០

គោលរៀននាទា ...... ២០៛០០

ថ្លៃ ១៧៛០០